# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ ចេញផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភ៉ិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា ស្វរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ភ៉ិយ-ប៊ុក ក្រមការ | នរិទមហន្ធៈគន្ធី (ត-ចប់) | ៨៨១ |
| — — | ប្រវត្តិសាស្ត្រនៃស៊ីវិល្បខ្មែរបុរាណ (តទៅ) | ៨៩២ |
| លោក ម៉ុញ-តាត្រី | ស័ព្ទបារាំងប្រែជាខ្មែរ (តទៅ) | ៩០១ |
| លោកសាង-សារ៉ិត លេខានុការ | រឿងព្រែនភូមា (តមក) | ៩០៥ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក) | ៩១២ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | ៩២២ |
| វិនយធរគណ ចៅអធិការ | សាវតារវត្តបាចិនាភប (តមក) | ៩២៨ |
| លោកផេង-ដិរ | ប្រវត្តិរបស់អសុប (តមក) | ៩៣៣ |
| **ផ្នែកសាសនា** | | |
| លោក ភ៉ិយ-ប៊ុក ក្រមការ | គន្ធិអាស៊ីទ្វីប (តមក) | ៩៤០ |
| ឃុនបណ្ណាទុរ័ក្ស ប៊ូ-ប៊ូ | កំឡាំងនៃពាក្យញុះញង់ (ត-ចប់) | ៩៤៣ |
| **កំណត់នៃប្រវត្តិការណ៍** | | |
| ព្រះមហា កែ-អឿន | ពិធីសម្ពោធបើកសាលាធម្មវិន័យ នៅវត្តព្រះព្រហ្មរតន៍ សៀមរាប | ៩៥១ |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (ត-មក) | ៩៥៨ |

---

ឆ្នាំទី ២២ — លេខ ១២ ខែ ធ្នូ ឆ្នាំ ១៩៥០ — ដំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka


## *TABLE DES MATIÈRES*

**Partie littéraire :**


| | | page |
|---|---|---|
| M. Ray-Buc Kromokar | Paroles de Gandhi (suite et fin) .... | 881 |
| - id - | Histoire de l'ancienne civilisation Khmère (suite) .................. | 892 |
| M. Menh-Nakry ancien député | Recueil des mots traduits par la Commission Culturelle (suite) ......... | 901 |
| M. Sang-Savath Secrétaire au Ministère des Finances | Contes birmans ( suite )............. | 905 |
| Neak Oknha Vibularajaséna Nou-Kân | Histoire de SAMKOK ( suite )........ | 912 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite)............................ | 922 |
| Vinayadhâra Kon Chau athicar de cette pagode | Notice historique de la pagode de Pacinarâmâ (suite et fin)......... .. | 928 |
| M. Pheng Chhieu, professeur au Collège des Jeunes Filles | Biographie d'Esope (suite).......... | 933 |


**Partie religieuse:**


| | | |
|---|---|---|
| M. Ray-Buc Kromokar | La lumière de l'Asie (suite)........ | 940 |
| Khun Pannanuraksa Bou-Po | Les effets de la calomnie (suite et fin) | 943 |


**Notes et Chroniques**


| | | |
|---|---|---|
| Préah Moha Ker-Oeun | Fête de l'Inauguration de l'Ecole Dharmavinaya à la pagode de Préah Brahmaratana........................ | 951 |
| Ministère des Cultes | Nomination des nouveaux Chau-Addhikar (suite) ................. | 958 |



22e Année: N° 12 — Mois de Décembre 1950 — Prix d'abonnement: 145$00 par an

ÉCOLE FRANÇAISE (BIBLIOTHÈQUE) D'EXTRÊME-ORIENT

## ឱវាទមហាត្មះគន្ធី

# លោក រ៉ាយ-ប៊ុក ក្រុមការ នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺន អាំង (Jeune Inde)

(ត-ចប់)

---

៤៣ — ប្រជាជាតិណាដែលបណ្តោយឲ្យចិត្តតក់ស្លុតខ្លាចសេចក្តីស្លាប់ ប្រជាជាតិនោះមិនអាចទទួលនូវស្វ័យភាពបានទេ, បើប្រសិនណាជាបានស្វ័យភាព កំមិនអាចរក្សាស្វ័យភាពនោះឲ្យគង់វង់បានឡើយ ។

ជាតិអង់គ្លេសគេដាក់ជីវិតរបស់គេក្នុងហោប៉ៅអាវ ។ ពួកជាតិអា-ប៉់ទីងប៉ាថង់ (Pathans) យល់ថា សេចក្តីស្លាប់ជាសភាវៈចប់ប្បារម្ភបន្តិចបន្តួច ហើយបើកាលណាមានញាតិមិត្តអនិច្ចកម្ម គេមិនដែលសំដែងសេចក្តីសោកស្តាយអ្វីឡើយ ។ ស្ត្រីជាតិបូអែរ្ស (Boers) មិនដែលបានជួបប្រទះនឹងសេចក្តីខ្លាចតក់ស្លុតបែបនេះសោះ ។ ក្នុងសង្គ្រាមជាតិបូអែរ្ស, មានស្ត្រីជាតិនេះជាច្រើនម៉ឺននាក់នៅជាមេម៉ាយ ។ នាងទាំងនេះកាន់ចិត្តជាងបេក្ខា ។ ខ្ញុំយល់ថាមិនជាអ្វីឡើយ ត្រង់សេចក្តីស្លាប់នៃស្វាមីឬបុត្រា, ឲ្យតែមាតុភូមិរួចផុតពីសេចក្តីទុក្ខលំបាក; គិតនេះល្អបំផុតថែមទាំងប្រសើរណាស់ផង ។ ស្វាមីនៅរស់តើស្វាមីនោះមានប្រយោជន៍អ្វីខ្លះ បើមាតុប្រទេសធ្លាក់ចុះទៅកាន់ទាសភាព? ការដែលកប់ធាតុកូនដែលជាអនត្តាធម៌ (គេសាបសូន្យ) ហើយរក្សាទុកនូវសេចក្តីស្នេហានៃ

អាត្មន ដែលជាអមតធម៌ (ធម្មជាតិមិនចេះស្លាប់) ប្រសើរជាងទុក គួននោះឲ្យរស់នៅក្នុងអនិច្ចភាព ។ ព្រោះហេតុដូចនេះបានជាស្ត្រីជាតិប្រែប្រួលមានសន្តានចិត្តរឹងប៉ុងដូចដែក ហើយបូជានូវបុគ្គលដែលជាទីស្រឡាញ់ ពេញចិត្តរបស់ខ្លួន ឲ្យទៅស្ដេចមច្ចុរាជដោយហាសនចិត្ត ។

...អាត្មននៃអ្នកស្លាប់នឹងអាត្មននៃអ្នករស់ បើតាមពិនិត្យទៅ រួបរួមមកមានតែមួយដូចគ្នា ។

...សេចក្ដីទុក្ខដែលគេទទួលដោយសេចក្ដីរីករាយ មិនមែនជាទុក្ខទេ ត្រឡប់ទៅជាសេចក្ដីសប្បាយស្រួលអស្ចារ្យ ។ មនុស្សដែលជួបប្រទះនឹងសេចក្ដីទុក្ខហើយមានចិត្តញញើតពេលទុក្ខនោះ តែងជួបប្រទះនូវសេចក្ដីព្រួយបារម្ភជានិច្ច ; បើទុកជាសេចក្ដីលំបាកនេះមិនទាន់មកដល់ បុគ្គលនោះទៅជាភ័យតក់ស្លុត, ហើយបើសេចក្ដីលំបាកនោះមកដល់ខ្លួនវេលាណា បុគ្គលនោះទៅជាញាប់ញ័រដូចជាស្លាប់មួយកំណាត់ខ្លួន ។ អ្នកណាដែលប្រមូលខ្លួនចាំទទួលនូវសេចក្ដីលំបាកគ្រប់យ៉ាងដោយចិត្តខន្តីសោរច្ច: អ្នកនោះមុខជានឹងរួចផុតពីសេចក្ដីទុក្ខនោះបាន ព្រោះការកាន់ខន្តីនឹងសោរច្ច: អាចធ្វើឲ្យអ្នកទទួលទុក្ខទៅជាសុខស្រួលដូចជាគេហិតនូវអពេតនុសថ (Anesthésique) ។

...សិទ្ធិធ្វើឲ្យមនុស្សខ្វាក់បុប្ផង; មនុស្សនោះមិនអាចនឹងមើលឃើញនូវវត្ថុដែលនៅចំពោះមុខខ្លួន ឬស្ដាប់សព្ទសំឡេងដែលមានមកដល់ត្រចៀកខ្លួនបានទេ ។

...ខ្ញុំយល់ឃើញថា: ពួកស្នេហាជាតិគួរហាក់ចិត្តទុកជាមុនប្រុងប្រៀបជាស្រេចនូវការទទួលស្លាប់, ទទួលរងលំបាកដោយការជាប់ពន្ធនាគារ (គុក) ឬទទួលរងនូវយថាកម្មដែលមានសភាពដូចខាងលើ ។

បុគ្គលអ្នកក្លាហានតែងត្រូវដើរទៅចំពីមុខសេចក្តីស្លាប់, មានបបូរមាត់ញញឹម មុខរីកស្រស់ តែពេលដូចនេះមិនមែនហាមឃាត់មិនឲ្យបុគ្គលការពារខ្លួនទេ បើសិនណាជាត្រូវការពារបាន ។

សេចក្តីខ្លាចស្លាប់
(១៣ ខែតុលា ១៩២០)

៥៤– ស្វ័យភាព បានខាងសេរីភាពចំពោះបុគ្គលម្នាក់ៗ គឺចំពោះបុគ្គលជាសាមញ្ញ (ដូចយើង) ក្នុងការដែលធ្វើបានតាមអំពើចិត្ត ដោយមិនមានឧបសគ្គមករាំងរាមិនឲ្យសេរីភាពប្រព្រឹត្តទៅបាន ។ ការដែលមិនព្រមធ្វើតាមបង្គាប់រាជការ ដោយប្រើអវិហឹសាចរិយា គឺជាវិធីដែលយើងត្រូវធ្វើនូវមតិមហាជនឲ្យចំរើនដោយសេរី ហើយនឹងយកមតិទាំងនោះទៅអនុវត្តនាការឲ្យបានផលប្រយោជន៍ឡើងតាមលំដាប់ ។ បើកាលណាមានសេរីភាពក្នុងការបញ្ចេញនូវមតិផ្សេងៗ ត្រូវយកមតិភាគច្រើនសម្រេចជាគោលច្បាប់; បើយើងនៅក្នុងចំណោមមតិភាគតិច បើទុកជាមានគេបង្ខំយ៉ាងណាក៏ដោយ យើងត្រូវតែទទួលដោយចរិយាថ្លៃថ្នូរតាមសាសនារបស់យើង ។

ចំពោះយោបល់នៃសីលធម៌
(២៤ ខែមេសា ១៩២១)

៥៥ – ស្វ័យរាជ្យ គឺសម្បូរវត្តន៍នៃរដ្ឋាភិបាល ដោយការធ្វើឲ្យកិច្ចការពិនិត្យត្រួតត្រាផ្ទាល់ទៅលើកណ្ដាប់ដៃប្រជារាស្ត្រ ។ តែសភាពបែបនេះគ្រាន់តែជាទម្រង់ក្រៅ, បំណែកខាងអត្ថរសនៃស្វ័យរាជ្យដែលខ្ញុំមានបំណងយ៉ាងមាំមួន គឺការទទួលនូវមធ្យោបាយជាក់ច្បាស់គ្រប់យ៉ាង ជាហេតុនាំឲ្យប្រែប្រួលនូវចិត្តប្រជារាស្ត្រពិតប្រាកដ ។

ការអនុវត្តន៍នូវកម្មវិធីនេះតាមសេរីប្រកបដោយប្រាជ្ញានៃប្រជាជាតិ នាំឲ្យឃើញថា ឲ្យគោលសំខាន់ៗ នៃសម្បូរវត្តន៍នឹងបានសម្រេចពិតប្រាកដ ។ បដិមារូបនៃសម្បូរវត្តន៍នេះ គឺការផ្ទេរនូវសិទ្ធិទាំងប៉ុន្មានដែលអាចធ្វើបានតាមបំណង ដូចជាគ្រាប់ឈើដែលព្រោះសាបដោយល្អ ត្រូវតែពន្លកដុះលូតលាស់ផ្សាយឡើងជាដើមឈើមួយ ។

ការពិនិត្យឃើញ

(១៣ ខែវិច្ឆិកា ១៩៦៦)

៥៦ – ស្វ័យរាជ្យមិនមែនប្រជាជាតិមួយឲ្យដល់ប្រជាជាតិមួយបានទេ គឺជាវត្ថុវិសេសមួយ ដែលយើងត្រូវទិញដោយលោហិតដ៏បរិសុទ្ធរបស់ប្រជាជាតិ ។ ហេតុនេះ ស្វ័យរាជ្យមិនមែនជាអំណោយអំពីអ្នកណាទេ ព្រោះយើងត្រូវទិញថ្លៃសម្បើមអស្ចារ្យ ។

ឯករាជ្យ

( ៥ ខែមករា ១៩៦៦ )

៥៧ – ករណីយកិច្ចដែលប្រទេសត្រូវបំពេញភ្លាមៗ គឺត្រូវឲ្យគ្រប់ជាតិឲ្យមានសេរីភាពក្នុងការនិយាយ, សេរីភាពក្នុងការប្រមូលបក្សពួកសមាគម និងសេរីភាពក្នុងការឃោសនាផ្សាយតាមសារពត៌មាន កុំឲ្យធ្លាក់ចុះទៅក្នុងសភាពជាមនុស្សពិការគ្មានសិទ្ធិធ្វើអ្វីបាន ។

លិខិតលោកមហាត្មៈគន្ធីផ្ញើទៅលោករបាដជតស្ហៀ
៩ ខែកុម្ភៈ ១៩២២

៥៨ – ធ្វើចិត្តមិនស្មោះស្ម័គ្រ ១.០០០ ដង ចំពោះអ្នកដទៃមិនជាការអ្វីទេ, តែកុំគប្បីធ្វើចិត្តមិនស្មោះស្ម័គ្រចំពោះខ្លួនឯងឲ្យសោះ ។

... មានតែវិធីមួយទេដែលត្រូវប្រើក្នុងកិច្ចផ្ដន្ទាទោសចំពោះបុគ្គលដែលយើងស្រឡាញ់ពេញចិត្ត គឺត្រូវខ្លួនយើងធ្វើចិត្តខន្តីស៊ូទទួលទុក្ខទោសលំបាកគ្រប់យ៉ាង ដែលកើតពីសេចក្ដីស្នេហានោះ ។

បទឧក្រិដ្ឋដែលធ្វើទៅទីក្រុង សៅរី-សោរ៉ា
១៦ ខែកុម្ភៈ ១៩២២

៥៩ – ពន្ធនាគារ (គុក) សម្រាប់ដាក់ពួកមនុស្សដែលប្រព្រឹត្តបទឧក្រិដ្ឋមកយូរហើយ មិនមែនជាទ្វារដែលនាំមនុស្សនោះទៅកាន់សេរីភាពបានឡើយ ។

យូរឆ្នាំមកហើយ ពិតមែនតែមានពួកជាតិរុស្សីជាច្រើនសែននាក់រងទុក្ខលំបាកនៅពន្ធនាគារនៃសហភាពរុស្ស៊ី, ប្រទេសនេះក៏មិនទាន់បានសេរីភាពនៅឡើយ ។

. . . សេរីភាពជាអាហារដ៏មួយលំបាកនឹងប្រើអាកប្បកិរិយាឲ្យសុខចិត្តប្ដូរផ្ដើបុកពាឲ្យត្រូវបិត្ត ។

. . . ជាតិអង់គ្លេសជាជាតិក្រអើតក្រទម ជាតិនេះមិនអាចយល់នូវឧទ្ធៈនៃជាតិយើងបានទេ ហើយពួកនេះលើកតំកើងខ្លួនជាអរិយបុគ្គល ។ ជាតិនេះយល់ថា ខ្លួនគេកើតមកក្នុងលោកសន្និកសស្រមាប់តែឲ្យជនជាតិយើងស្តាប់បង្គាប់ប៉ុណ្ណោះ ហើយគេអាងមានកាំភ្លើងធំនឹងពលភាពនៃកងទ័ពសម្រាប់ការពារខ្លួនគេផង ។

. . . កណ្ដារមិនអាចបៀសពីគ្នាបាន កណ្ដារមិនអាចសន្ទនាការជាមួយនឹងគ្នាបាន បើគ្នាមិនកាត់ក្រចកនឹងធ្មេញចេញ ។

. . . ទោសកំហុសនៃរដ្ឋាភិបាល នាំឲ្យជឿជាក់នូវឧត្តមគតិរបស់យើង ។ ទោសកំហុសនៃក្រុមយើង ជាការទំនាស់នឹងរដ្ឋាភិបាល ។

គណៈកម្មាធិការនៃសភាកុងក្រេស៍ប្រទេសឥណ្ឌា

២ - ៣ - ១៩២២

## B). ដកស្រង់ពីសៀវភៅ ឡែត្រអាឡ្យាស្រម

(Lettres à l'Ashram).

៦០ – ត្រង់ណាដែលមានសច្ចធម៌ ត្រង់នោះក៏មានវិជ្ជាពិត ។

៦១ – សច្ចធម៌ត្រូវទុកជាមូលហេតុនៃកម្មកភាពរបស់យើង ។

៦២ – ចិត្តមិនអាចរកសុខឃើញទេ បើគ្មានវិជ្ជាពិត ។

៦៣- វត្តពិតបើពិនិត្យដោយស្ពាន ទើងឃើញថាមានសភាព ផ្សេងៗគ្នា ប្រៀបដូចជាស្លឹកឈើមានច្រើនឥតគណនា តែមានលក្ខណៈ ខុសពីគ្នា សូម្បីដុះរួមនៅទីងដើមតែមួយ ។

៦៤- បើសេចក្តីស្នេហាប្រកបដោយអត្តទត្ថភាពហើយមានក្រប ខ័ណ្ឌ មុខជានឹងមានឱកាសបន្តប្រណោះគ្នាកាន់តែច្រើនៗឡើង ។

៦៥- បើចិត្តវង្វើងហើយ រូបមិនយូរក៏ធាប់ គង់តែប្រព្រឹត្តទៅ តាមចិត្តមិនខាន ។

៦៦- អ្នកណាមានធនុៈ ចង់ធ្វើអគ្គការណាមួយក្នុងវ័ន្តឲ្យនៅ ក្រោមបង្គាប់អាត្មា ត្រូវកំណត់ទុកក្នុងចិត្តជាដាច់ខាតថានឹងធ្វើអគ្គការ ឯទៀតៗ ឲ្យនៅក្រោមឱវាទខ្លួនផង ។

៦៧- ឱសថដែលគេផឹកមានប្រមាណតិចពេក រមែងមិនមានផល ឬមិនអាចឲ្យផលពេញលេញ; បើគេផឹកឱសថនោះច្រើនហួសប្រមាណ ត្រឡប់ជាឲ្យទុក្ខលំបាកដល់ខ្លួនវិញ ។

៦៨- អ្នកណាដែលមានចិត្តសន្តោសករុណាកត្តាហារ ដល់យូរទៅ មុខជានឹងហាក់ចិត្តឲ្យជាឯកគ្គតាបាន ។

៦៩- យើងមិនត្រូវគិតប៉ាក់ខ្លួនដោយខ្លួនឯង ដោយប្រើកល ល្បិចបែបណាទេ ។

៧១ – បើផ្ដើមគតិណាមួយឲ្យវិបុលភាព ឬឲ្យវិនាសអន្តរាយដោយសារការបង្ខំឲ្យខ្លួនឯង គឺការមិនប្រតិបត្តិតាមសច្ចធម៌, អំពើយ៉ាងនេះឈ្មោះថាផ្ដើមខ្លួនឯងឲ្យទាបថោក ។

៧១ – បើយល់ច្បាស់នូវឧត្ដមគតិណាមួយហើយព្យាយាមប្រឹងប្រែងជាអនេកប្បការដើម្បីនឹងត្រូវសំរេចទៅតាមឧត្ដមគតិនោះ, បើទុកជាឧត្ដមគតិនោះមានសភាពលំបាកយ៉ាងណាក៏ដោយ គេទុកថាការពិសោធន៍នោះជាចរិយាដ៏ថ្លៃថ្លា ។

៧២ – ពួកសេដ្ឋីប្រមូលវត្ថុដែលមិនជាប្រយោជន៍សំខាន់ច្រើនឥតគណនា ហើយយកមកចាយតាមអំពើចិត្ត, ចំណែកមនុស្សទាំងកោដិនាក់ស្លាប់ដោយសេចក្ដីស្រេកឃ្លានគ្មានអាហារបរិភោគ ។

៧៣ – ពាក្យ " ស៊ីវិល្ស " បើតាមពិត មិនមែនផ្ដល់វត្ថុដែលត្រូវការនោះឲ្យបរិបូរទេ គឺត្រូវបន្ថយចំនួននៃវត្ថុទាំងនោះដោយចិត្តស្មោះស្ម័គ្រ ។

៧៤ – សាសនាឯកនោះគឺស្ថិតនៅក្នុងផែនដោយឡែក មើលមិនឃើញថាមិនត្រូវ ។

៧៥ – អ្នកណាដែលយកជីវិតធ្វើពលិកម្មចំពោះអ្នកដទៃ អ្នកនោះមិនមានឱកាសនឹងការពារទ្រព្យខ្លួន ដែលខ្លួនត្រូវបាននៅក្រោមព្រះភាគ្យទេ ។

៧៦ – ទឹកមួយតំណក់ដែលឃ្លាតចេញពីមហាសាគរអាចឈប់សំកុកបានមួយពេលមួយខណៈ តែទឹកមួយតំណក់ដែលស្ថិតនៅក្នុងសាគរគ្មានឱកាសនឹងឈប់សំកុកបាននោះឡើយ ។

៧៧ – គ្រាន់តែពិនិត្យបន្តិចបន្តួច យើងអាចយល់ច្បាស់ឥតសង្ស័យថា " សត្វដែលមានជីវិតរស់នៅក្នុងលោកសន្និវាសនេះ គឺជាបរមាណូមួយតិចតួចស្តួចស្តើងណាស់ក្នុងចក្រវាឡ " ។

៧៨ – សច្ចធម៌ស្វិតរឹងដូចពេជ្រ ហើយផុយដូចបុប្ផានៃរុក្ខជាតិ "ប៉ែស្សេ" (pêcher) ។

៧៩ – សកលលោកត្រូវសំរេចដោយច្បាប់ព្រហ្មវិហារ ។ ពិតមែនតែមានសេចក្ដីស្លាប់ តែជីវិតស្ថិតនៅជាដរាប ។ ចក្រវាឡនេះតែធ្វើដំណើរលឿនទៅមុខ ពិតមែនតែមានវិនាសកម្មជានិច្ច ។ ធម៌ពិតឈ្នះធម៌មិនពិត ។ សភាពស្រឡាញ់ ឈ្នះសេចក្ដីស្អប់ ។ ព្រះឈ្នះជានិច្ចលើស្ដេចបិសាច ។

៨០ – ការពារទ្រព្យសម្បត្តិ, កិត្តិយស និងសាសនារបស់ខ្លួនដោយចុងដាវជាកិច្ចដ៏ឧត្តម ។ ការពារវត្ថុខាងលើនេះ ដោយកុំធ្វើទារុណកម្មដល់ពួកបច្ចាមិត្តរបស់ខ្លួន នេះជាកិច្ចប្រសើរបំផុត ។

៨១ – សាសនារបស់ខ្ញុំទូន្មានប្រដៅខ្ញុំថា "បើខ្ញុំទញ់គុំគំនិតចំពោះវត្ថុណាមួយ ដែលខ្ញុំមិនអាចរកមធ្យោបាយប្តុសុចកែបានទេ ខ្ញុំត្រូវអត់អាហារហើយសូត្រធម៌ " ។

៨២ - កន្លងមួយៗ ធម្មជាតិតែងឲ្យផលានុផលល្មមចិញ្ចឹមជីវិតបានគ្រប់គ្រាន់បរិបូណ៌ ។ បើកន្លែងម្នាក់ៗ បរិភោគអាហារល្មមសមគួរ, នៅក្នុងលោកក៏គ្មានអ្នកកំសត់ទុគ៌តទេ ទាំងគ្មានអ្នកស្លាប់ដោយសារអត់បាយ ។

៨៣ - ជីវិតគ្មានសាសនា គឺជីវិតគ្មានគោលការណ៍ ហើយជីវិតគ្មានគោលការណ៍ទុកដូចជានាវាគ្មានចង្កូត ។

៨៤ - ខ្ញុំមិនព្រមអនុម័តតាមលទ្ធិសាសនាណាដែលមិនយកវិចារណញ្ញាណជាមូលហេតុ ដែលប្រើវិធីជំទាស់នឹងសីលធម៌ ។ ខ្ញុំយល់ព្រមអនុម័តតាមមនោសញ្ចេតនាខាងសាសនា ដែលមិនប្រកបទៅតាមវិចារណញ្ញាណ តែមានសភាពមិនផ្ទុយគ្នានឹងសីលធម៌ ។

៨៥ - បុគ្គលមានចំនួនប៉ុន្មាន, សាសនាក៏មានចំនួនប៉ុណ្ណោះ ។

៨៦ - សាសនាប្រៀបដូចជាផ្លូវមានសភាពផ្សេងៗគ្នា តែរួមចូលក្នុងស្ថានទីបំណងតែមួយ ។ មិនជាអ្វីទេ ទោះបីយើងត្រាច់តាមផ្លូវផ្សេងៗគ្នាក៏ដោយ ឲ្យតែយើងទៅដល់ស្ថានទីបំណងដូចគ្នា ។

៨៧ - វិធានវិសេសនៃការប្រព្រឹត្តិរបស់យើង គឺយើងត្រូវធ្វើចិត្តសន្តោសទៅវិញទៅមក, ដោយហេតុថាយើងមិនមានមនោគតិដូចគ្នា ហើយយើងអាចឃើញនូវសច្ចធម៌តាមបែបដែលយើងគួរឃើញ ហើយតាមយោបល់ផ្សេងៗគ្នាទាំងអស់ ។ មនសិការនៃបុគ្គលទាំងអស់មិន

ដូចគ្នាទេ ។ មនសិការនេះអាចធ្វើជាមគ្គុទ្ទេសក៍ ដ៏ប្រសើរចំពោះការប្រព្រឹត្តិរបស់យើង ។ តែបើយើងបង្ខំឲ្យអ្នកឯទៀតប្រតិបត្តិតាមគោលការរបស់យើង គេទុកយើងជាអ្នករំលោភនូវសិទ្ធិនៃបុគ្គលនីមួយៗ ចំពោះសេរីភាពនៃមនសិការ ។

៨៨ - ប្រទេសនីមួយៗ ត្រូវមានសេរីភាពដើម្បីនឹងយកជីវិតទៅធ្វើពលិកម្មជាប្រយោជន៍សកលលោក បើកាលណាគេត្រូវការ ។ ព្រោះហេតុដូចនេះ មតិរបស់ខ្ញុំ ចំពោះលទ្ធិប្រជាជាតិនិយម, សេចក្ដីស្នេហារបស់ខ្ញុំចំពោះលទ្ធិនេះ គឺខ្ញុំមានបំណងស៊ូឲ្យប្រទេសខ្ញុំស្លាប់ចុះ ឲ្យតែជាតិមនុស្សក្នុងសកលលោកមានជីវិតរស់នៅ ។

៨៩ - សាសនារបស់ខ្ញុំមិនមានព្រំដែនតាមភូមិសាស្ត្រទេ បើខ្ញុំមានសទ្ធាដ៏ខ្លាំងក្លា, សទ្ធានោះមានពលភាពហួសសេចក្ដីស្នេហារបស់ខ្ញុំចំពោះប្រទេសឥណ្ឌាទៅទៀត ។

៩០ - កុំឲ្យជឿថា ខ្ញុំប្រមាថមើលងាយនូវធម្មជាតទាំងអស់ដែលចេញមកពីខាងបច្ចិមប្រទេស ។ មានធម្មជាតជាច្រើនដែលខ្ញុំបានផ្ទេរយកមកទុកជារបស់ប្រទេសនេះ ។

# ប្រវត្តិសាស្ត្រនៃស៊ីវិល័យខ្មែរបុរាណ

លោក ស័រស៍-ស៊ឺដែស តែង

## លោកវ៉ាយ-ប៉ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

---

ពួកទាំងនេះត្រូវធ្វើការពេលថ្ងៃ ទាំងត្រូវបង់ប្រាក់ដែលអ្នកកសាងវត្តបានបង្គាប់ឲ្យធ្វើបង មានអនុក្រុម្នាក់ត្រួតត្រាពួកទាំងប៉ុន្មានបែងជាពីរក្រុម ក្នុងមួយក្រុមៗ ត្រូវធ្វើការមានវេនផ្លាស់គ្នាក្នុង ១ ខែ ១៥ ថ្ងៃជាលំដាប់ ៗ

ភោគទ្រព្យនៃប្រាសាទ វត្តទាំងនោះមានច្រើនឥតគណនា ៗ បដិមារូបមួយធ្វើពីសិលាដំកល់ទុកនៅក្នុងវត្តចំពោះខែត្រនីមួយៗ មានគ្រឿងអលង្ការពេញបរិបូណ៌ គឺមានគ្រឿងមាសនឹងប្រាក់មកុដពជ្រ, កងក, ខ្សែខ្លួន, កាវពាក់ត្រចៀក, ចិញ្ចៀន, ខ្សែដៃ, កងជើង ៗ ឃ្លាំងនៃវត្តប្រាសាទនេះ មានគណ្ឌីសម្រាប់ធ្វើពិធីនឹងគ្រឿងប្រដាប់ឯទៀតជាច្រើនរចនាដោយមាស, ប្រាក់, ស្ពាន់ប្រុលង់ហិន ៗ ដល់មកចុងសតវត្សទី ១២ ប្រាសាទដែលជាស្តូបសម្រាប់ដំកល់អដ្ឋិធាតុ មានភោគទ្រព្យសំបើមអស្ចារ្យ ដែលគេបានធ្វើបញ្ជីចុះនាមរបស់ដោយពិស្ដារ ៗ នៅប្រាសាទតាព្រំដែលជាប្រាសាទកសាងចំពោះព្រះជននីនាថ សិទ្ធិត្រួតត្រាលើភូមិ ៣.១៤០ ពុជបរិវារ ៧៩.៣៦៥ នាក់ ៗ ក្នុងចំនួនពុជបរិវារនេះមាន

១២.៦៤០ នាក់ ដែលនៅប្រចាំក្នុងកំពែងប្រាសាទ ។ ក្រៅពីនេះមានលោកសង្ឃដែលជាចៅអាវាស ១៨ អង្គ. លោកសង្ឃសម្រាប់សូត្រពិធី ២ ៧៤០ អង្គ, អ្នកប្រជាំសង្គ្រោះ ២.២០២ នាក់, នាងនាដកា ៦១៥ នាក់ ។ ប្រាសាទនេះមានឃ្លាំងមួយមានសុវណ្ណភាជនៈ មួយទម្ងន់ ៥ ០០០ គីឡូ, មានភាជនៈប្រាក់ជាច្រើន, មានត្បូងពេជ្រ ៣៥ គ្រាប់, កែវមុក្តា ៤០.៦២០ គ្រាប់ និងត្បូងឯទៀតជាច្រើនចំនួន ៤.៥៤០ គ្រាប់, មានសុវណ្ណកិង្ការមួយធំព្រមទាំងមុងស្បៃប្រទេសចិន ៩៦៧, គ្រែសំពត់ព្រែ ៥១២ ឆ័ត្រ ៥២៣ ... ។

ក្រមព្រះនគរបាលនៃព្រះវិហារទាំងនោះបានបញ្ញត្តិតឹងរឹង គឺហាមមិនឲ្យចូលទៅក្នុងប្រាសាទឬព្រះវិហារទាំងនោះ ដោយជិះសេះឬបាំងឆ័ត្រ, ត្រូវតែទទួលដោយរាក់ទាក់នូវអ្នកដំណើរ, ចិញ្ចឹមអ្នកក្រលំបាក, មនុស្សចាស់ ហើយត្រូវគោរពអ្នកទាំងនោះតាមឋានន្តរស័ក្តិខ្ពស់ទាប: ពួកព្រាហ្មណ៍, ព្រះអង្គម្ចាស់, មន្ត្រី, មេទ័ព ។ មួយវិញទៀត ប្រាសាទដែលកសាងសម្រាប់សាសនាមានសិទ្ធិដោយឡែក គឺមិនមានកំណែន, មិនបង់ពន្ធធម្មជាតិ, មិនបង់ពន្ធឲ្យរាជកណ្ឋាគារ (Magasins royaux) មិនត្រូវនៅក្រោមបង្គាប់នៃរាជការខេត្ត, ត្រូវនៅក្រោមបញ្ជាការនៃអំណាចវង្សត្រកូលពួកជនកៈ ឬលោកសង្ឃ ដែលពួកជនកៈបានផ្ទេរអំណាចឲ្យគ្រប់គ្រា ។ អក្សរនៅក្នុងសិលាចារឹក គឺពណ៌នាអំពីសិទ្ធិទាំងនោះនិងរៀបចំនូវកេតនភណ្ឌ (Attributs) សព្វ ខ្ទួន ។

ពីកាលមុននោះ ខ្ញុំបានអធិប្បាយអំពីរាជបរិយាយនៃព្រះមហាក្សត្រ ប្រៀបធៀបទៅនឹងព្រះ គឺជាបដិមារូបនៃព្រះមហាក្សត្រសម្មតិជាព្រះ មួយអង្គ ព្រមទាំងនាមបដិមា (Symbolisme) នៃព្រះរាជនគរដែលស្ថាបនា ឡើងមានលំនាំជាតំណាងចក្រវាឡជាខុទ្ទកភាព (En miniature) យើង អាចយល់បានថាកិច្ចការក្នុងនគរ ដែលយើងទុកជាកិច្ចរបស់គ្រហស្ថត្រ-ឡប់ទៅជាកិច្ចការខាងសាសនា បុរាណទំនៀមទម្លាប់ប្រពៃណីទៅវិញ ។ ព្រះវិហារដែលនៅចំកណ្ដាលព្រះរាជនគរ ដែលមានស្ថានភាពទ្រង់ទ្រាយជាចេតិយ គឺសម្មតិនាមជាភ្នំព្រះសុមេរុដែលនៅចំកណ្ដាលលោក, កំពែងព្រះវិហារនោះជាបរិវារភ្នំព្រះសុមេរុដែលព័ទ្ធជុំវិញចក្រវាឡ, ព្រែកជីកដែលរចនាប្រៀបទៅនឹងមហាសាគរ ដែលនៅបាតភ្នំព្រះសុមេរុ នឹងជួរភ្នំឯទៀត, ស្ពានដែលមានរបាំងជារូបនាគនោះគឺជាឥន្ទធនូដែលជាផ្លូវគមនាគមចំពោះពិភពលោក:ទៅកាន់សុវណ្ណភូមិ, ប្រាសាទតូចៗ ដែលមានរចនាខាងក្រោមដោយរូបបក្សានោះ គេទុកជាប្រាសាទឬវិមាន អណ្ដែតដែលមានទេវតាឥន្ទព្រហ្មស្ថិតនៅក្នុងទីនោះ ។

មិនតែប៉ុណ្ណោះ ការចាប់ដីទំនេរឬគេបោះបង់ចោល ព្រមទាំងចាត់មនុស្សឲ្យទៅតាំងទីលំនៅៗ ទីនោះ សុទ្ធតែមានរៀបពិធីខាងសាសនា ដែលជាឡាក់គោលនៃកម្មិកភាពជាតិខ្មែរសម័យបុរាណ ។ ខ្ញុំមិនមែនពោលថាកិច្ចការទាំងអស់ចំពោះការដែលយកផលពីព្រះធរណីនោះ មាន

សាសនាជាបុព្វហេតុ តែបើតាមពិត កិច្ចការកសាងវត្ត ឬសាងប្រាសាទ សម្រាប់ដាក់អដ្ឋិធាតុនីមួយៗ ត្រូវបង្កើតឲ្យមានភូមិមួយឬច្រើន ហើយចាត់បរិករឲ្យទៅតាំងទីលំនៅៗ ភូមិនោះ ព្រមតាំងជីកស្រះជាប្រយោជន៍ដល់ព្រះវិហារឬប្រាសាទតាំងនោះ នឹងប្រជារាស្ត្រជាច្រើនដែលត្រូវទៅថែទាំបោសសំអាតព្រះវិហារ ។

សិលាចារឹកទាំងប៉ុន្មានបានពណ៌នាអំពីការជីកស្រះឬទទកប្បទេស (pièces d'eau) ជាច្រើនកន្លែង ; កិច្ចការនេះសំខាន់បំផុតចំពោះប្រទេសនេះ, បើគ្មានទឹក គ្មានការជីកព្រែកស្រោចដំណាំ ដីដែលបែកបដោយខ្សាច់ច្រើនទៅជាគ្មានផល ។ ក្បួនធារាសាស្ត្រនៅភូមិភាគអង្គរជាស្នាព្រះហស្តសមៀមអស្ចារ្យ នៃព្រះមហាក្សត្រិយ៍ជាច្រើនសន្តតិវង្សដែលពួកអ្នកឯកទេស (spécialistes) បានកោតសរសើរជាអនេកប្បការក្នុងរឿងនេះ ។ ក្នុងពេលមុននេះ, គេបានចាត់តាំងក្បួនធារាសាស្ត្រកសិកម្ម (hydraulique agricole) ដោយប្រើព្រែកជីកទាំងប៉ុន្មាន ព្រមទាំងលៃលកនូវស្រះបារាយខាងត្បូងដែលជាស្រះធំ ជីកពីកាលសតវត្ស ១១ ស្ថិតនៅខាងលិចអង្គរឲ្យមានទឹកបរិបូណ៌ឡើង, កិច្ចការនេះ អាចធ្វើឲ្យវាលស្រែនៅទីនេះមានផលសម្បូណ៌ឡើងបាន ។ ស្នាព្រះហស្តនៃព្រះមហាក្សត្រិយ៍សម័យបុរាណ ដែលគេមិនយកមកអនុវត្តនាការជាច្រើនសតវត្សមកហើយ នាំធ្វើឲ្យភូមិភាគដែលសម្បូណ៌ហើយមានពលរដ្ឋ

ជាច្រើន ទៅជាផលបងក្រីក្រលំបាក់ទៅវិញ ។ ស្ពានព្រះហស្តនោះមាន បំណងចង់ឲ្យមានប្រយោជន៍ដល់ប្រជាជនទាំងអស់ តែបើតាមពិនិត្យគង់ មានបញ្ហាស្មុគស្មាញទៅលាយឡំជាមួយផង ។ ហើយចំពោះសិលាចារឹក ដែលស្ថិតនៅទាំងបួនជ្រុងនៃស្រះបារ៉ាយខាងកើត ដកពីចុងសតវត្ស ៩ ខាងកើតព្រះរាជធានី ត់ឡូវ៉េងទឹកអស់, ព្រះមហាក្សត្រិយ៍ យសោវរ្ម័ន ព្រះអង្គទ្រង់មានព្រះបន្ទូលសួរសីហនាទចំពោះស្ពានព្រះហស្តនេះ ហើយ ទ្រង់បានធ្វើព្រះរាជបណ្តាំដល់ព្រះរាជទាយាទនឹងស្តេចដែលសោយរាជ្យ ក្រោយតមកទៀតថា: " សូមឲ្យការពារនូវព្រះរាជកុសលដ្ឋានទាំងនេះ"; នៅទីនេះ ព្រះអង្គបានប្រើពាក្យដែលគេសម្រាប់ប្រើខាងព្រះវិហារដែល សាងសម្រាប់សាសនា ដែលមានហេតុទាក់ទងចំពោះគុណសម្បត្តិទៅ បរលោក ។

ផលប្រយោជន៍ ដែលបានពីដីដោយយកទឹកស្រះនេះស្រោចទឹង ចំនួនពួកក្សេត្រករដែលយកមកប្រើក្នុងកិច្ចនេះ, គេអាចយកមកធ្វើជា របៀបពិនិត្យគ្រោងការគួរជាទីពេញចិត្តអ្នកនិពន្ធ ដោយកត់ស្រង់វត្ថុធាតុ ទាំងប៉ុន្មានដែលមានក្នុងសិលាចារឹកនោះ ។ ដីដែលជាកម្មសិទ្ធិនៃព្រះ វិហារបុប្ផាសាទទាំងនេះ, មានឯកសារបញ្ជាក់ដោយច្បាស់លាស់អំពី ទីកន្លែង, ចំនួន, របៀបដែលដីទាំងនោះបានមកពីពួកខាយក ។ គេ បានឃើញនូវការប្រែស្រ័យគ្នាទៅវិញទៅមកចំពោះពួកពាណិជ ដោយ

ពួកខ្មែរបុរាណមានប្រើក្បួនបកតិសំខ្យា (systéme numéral) [illegible] ហើយខ្មែរទាំងនោះមិនចេះប្រើរូបិយវត្ថុ ។

ជាតិខ្មែរ, បើតាមសេចក្ដីពិត បានរក្សាការជាងពួកជាតិឯទៀតដែលនៅក្នុងពូជប្រជាជាតិភាសាមន-ខ្មែរ (groupe ethno liagnistique mon-Khmer) តែចំពោះក្បួនបកតិសំខ្យា ឬបុរាណសំខ្យា នៅល្អជាងគេ ។ ចំណែកខាងជាតិពន្ធ, សម្រែ, ម៉ុយ មានពាក្យសម្រាប់ហៅគ្រប់គ្នាចំពោះលេខទាំងដប់; ជាតិខ្មែរចេះរាប់លេខត្រឹមតែ ៥; ឯលេខ ៦ ជាតិនេះពោលថា ៥+១; លេខ ៧, ៨, ៩ ពោលថា ៥+២, ៥+៣, ៥+៤ ។ តែឥឡូវ ជាតិខ្មែរមានពាក្យហៅ ៣០, ៤០, ៥០ ។ល។ ដោយខ្ចីពីសៀមយកមកប្រើ; ពីដើមមានតែពាក្យហៅថា: ១០, ២០, ៤០០; ឯពាក្យ ១០០ ហៅតាមភាសាសំស្ក្រឹតថា សត (çata) ។ លេខ ១៤៨ ពីដើមពោលថា: "មួយរយម្ភៃពីរដងប្រាំបី" (១០០, ២០ ពីរដង, ៥+៣); លេខ ៦៣៧ ពោលថា: "បួនរយ, ពីររយ, ម្ភៃមួយដង, ដប់, ប្រាំពីរ" (៤០០, ២០០, ២០ មួយដង ១០, ៥+២)។

បើតាមសិលាចារឹកមិនឃើញមានពោលអំពីរូបិយវត្ថុ (ប្រាក់) ហើយការដែលស្វែងគាស់គកាយរកតាមប្រាសាទ មិនដែលឮថាមានរូបិយបុរាណសោះឡើយ (វៀរលែងតែមានសកាពខ្ទះ ដែលកម្របានឃើញ គឺប្រាក់ដែលគេរកឃើញពីបុរាណសម័យនៅប្រទេសសៀម,

គូមា ឬសម័យនគរភ្នំ) ។ ព្រោះហេតុដូចនេះ, ការប្រាស្រ័យគ្នាទៅវិញទៅមក ដូចជាការរំញ្ញដ៏ដែលគេបានកត់ត្រាទុកនូវសិលាចារិកគឺធ្វើដោយការដូរគ្នាទៅវិញទៅមកដោយរបស់ផ្សេងៗមានដូចធ្វើនឹងលោហធាតុមានតម្លៃ ឬ ធ្វើនឹងស្ពាន់, គ្រឿងប្រដាប់ចំអិនអាហារជាច្រើន, ខោអាវ, សំពត់, អង្ករឬស្រូវ, សត្វពាហនៈ, ទាសករ ។ ការប្រែប្រួលជាច្រើនលើកក្នុងកំឡុងសតវត្សទាំងនោះ ចំពោះការយកវត្ថុរបស់យ៉ាងទៅដូរយកដីមានចំនួនប៉ុន្មានៗនេះ ជាការមានប្រយោជន៍សំខាន់ចំពោះប្រវត្តិការនៃកម្មសិទ្ធិអសង្ហារិមៈកម្ពុជ ។

ការលំបាកដោយប្រើក្បួនខ្នាតនូវលេខសំខាន់នឹងការប្រាស្រ័យគ្នាទៅវិញទៅមក គឺមកពីគ្មានរូបិយវត្ថុ ។ ព្រោះហេតុដូចនេះ ខ្ញុំសូមពណ៌នាអំពីរឿងរ៉ាវទាំងពីរបែបនេះ ឲ្យមានសេចក្ដីពិស្ដារបន្តិចដើម្បីនឹងបង្ហាញឲ្យឃើញថា ហេតុម្ដេចក៏ប្រទេសដែលស៊ីវិល័យដែលគេទុកថាវិសេសវិសាលចំពោះបញ្ហាខ្លះ ទៅជាមានគំនិតប្លែកគួរឲ្យសង្ស័យ ។

បញ្ហាខាងសម្ភារៈ ចំពោះដំណាក់កាលនៃខ្មែរបុរាណ, គេហដ្ឋានទាំងនោះ, គ្រឿងតុបតែង, គ្រឿងឧបភោគ, គ្រឿងការពារយុទ្ធភ័ណ្ឌ, កុលាលកាជន៍, របៀបធ្វើឆ្នាំង, ចាន, ថូ (céramique). ការត្បាញសំពត់, គ្រឿងអលង្ការសម្រាប់តែងខ្លួន គួរតែពណ៌នាឲ្យបានក្បោះក្បាយថែមមានរូបគំនូរជាច្រើនទៀត ។ កិច្ចពិនិត្យគ្រោងការនេះ លោកសិស្ស

គ្រូស្លីយេរ (Georges Groslier) បានរៀបចំតែងសៀវភៅលោកហៅថា រ៉ឺសែរស៍ ស៊ុរឡេកាំបូជស៊ុយាង (Recherche Sur les Cambodgiens) ដែលបានធ្វើជាពិពណ៌នា (partie descriptive) ដោយមានរូបគំនូរក្បាច់របនាអង្គរវត្ត និងប្រាសាទបាយ័នគួរជាទីទស្សនាពន់ពេក ៗ ចំពោះរឿងនេះមានសិលាចារឹកជាច្រើន ដែលបានអធិប្បាយពីបញ្ជីឈ្មោះវត្ថុផ្សេងៗ ដែលជាគ្រឿងអលង្ការនៃរូបចំឡាក់នឹងគោគទេព្យនៃប្រាសាទទាំងនោះ ៗ មានពាក្យដែលគេហៅនាមនៃវត្ថុទាំងនោះ ឥឡូវគេលែងប្រើហើយមិនអាចបកប្រែបាន តែគេអាចយល់បានថាជានាមវត្ថុដែលចារឹកទុកនឹងផែនសិលា គឺជានាមវត្ថុដែលមានក្នុងប្រាសាទនោះ ៗ ការនៅសល់ដែលយើងត្រូវព្យាយាមធ្វើតទៅទៀត ជាការមិនមែនងាយ គឺត្រូវស្វែងរកឲ្យនាមពិតនៃវត្ថុទាំងនោះយកទៅប្រៀបធៀបនឹងនាមនៃវត្ថុដែលបានកត់ត្រាទុកនៅសិលាចារឹក ៗ

ចំពោះអក្សរសាស្ត្រជាតិខ្មែរបានទុកកេរ្តិ៍តំណែលឲ្យយើងចំពោះតែសិលាចារឹកជាភាសាសំស្ក្រឹត ៗ អត្ថបទខ្មែរគ្មានតែពណ៌នាពីរឿងរ៉ាវក្នុងវាំង មិនអាចយកជាឡាក់គោលនៃអក្សរសាស្ត្របានឡើយ ៗ ឯអត្ថបទសំស្ក្រឹតសុទ្ធតែជាពាក្យកាព្យទាំងអស់ ប្រមូលទៅជាការនិទាន មានតែជាបឋមបទជាពាក្យប្រកាសខាងសាសនា ហើយខាងនាមរបស់ក្សត្រិយ៍នឹងសន្តតិវង្សនៃមហាពងដែលសោយរាជ្យក្នុងពេលនោះ

ដែលខ្ញុំបានយកអត្ថបទខ្លះមកចុះបង្ហាញពីមុនជាគំរូស្រាប់ហើយ មានបរិយោសានបទជាពាក្យសរសើរ នូវពួកទាយកព្រមទាំងបែបផែននៃការសាងប្រាសាទទាំងនោះ ។ សិលាចារឹកទាំងនោះបញ្ជាក់ឲ្យយើងយល់ច្បាស់នូវការផ្សាយឥទ្ធិពល ខាងវប្បធម៌សំស្ក្រឹតចូលមកប្រទេសកម្ពុជាសម័យបុរាណ ។ បើគេជឿជាក់នូវអារម្ភកថានៃពួកសាស្ត្រាចារ្យ និងពួកនិស្សិតក្នុងពេលនោះ, គេអាចដឹងបានថា វប្បធម៌សំស្ក្រឹតផ្សាយមកក្នុងប្រទេសនេះបានខ្លះ ហើយកែប្រែចំរើនតាមលំដាប់ក្នុងពេលដែលពួកព្រាហ្មណ៍ឥណ្ឌាចូលមកម្ដងៗ ។ បើតាមពិនិត្យយល់ឃើញចំពោះរឿងដែលបានពណ៌នាជាច្រើននិងចំណោះផ្សេងៗ ពិនិត្យគ្រោងការនេះត្រូវធ្វើទៅតាមមាតិកាដូចគ្នា និងមាតិកាក្នុងរឿងប្រទេសឥណ្ឌា គឺ: អត្ថបទចំនៀមទម្លាប់, ក្បួនទស្សនវិទ្យា, វេយ្យាករណ៍, ការដកស្រង់បញ្ញត្តិច្បាប់សាស្ត្រនិងតក្កសាស្ត្រ, វេជ្ជសាស្ត្រ ។ វីរនិទានកវីនិពន្ធ (poèmes épiques) នេះជាប្រភពដ៏សំខាន់ឬជាគតិនិម្មិតនៃពួកកវីទាំងប៉ុន្មាន ព្រមទាំងពួកជាងគំនូរនិងជាងឆ្លាក់ក្បាច់ជញ្ជាំងប្រាសាទ ។

(មានត)

# សព្ទបារាំងប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

## លោកម៉ុញ-ឆាំគ្រី អតីតតំណាងរាស្ត្រ រូបរួម

(តមក)

Lexique = សព្ទានុក្រម

Vocabulaire = វាក្យសព្ទ

Mot = ពាក្យ

Phrase = ប្រយោគ

Etymologie = និរុត្តិសាស្ត្រ

Etymologiste = អ្នកនិរុត្តិសាស្ត្រ

Syntaxe = វាក្យសម្ពន្ធ

Grammaire = វេយ្យាករណ៍

Grammairien = អ្នកវេយ្យាករណ៍

អង្គារ ២០ កុម្ភៈ ១៩៥០

Parti de l'Union démocratique = គណៈបក្ស "សហប្រជាធិបតេយ្យ"

Disciple = សាវ័ក

Condisciple = សមានាចារ្យ...

Un maitre sévère = គ្រូប្រឹងប្រែង

Un maitre inflexible = គ្រូមធ្យ័ត

ថ្ងៃ ៣០ ខែឧសភា ១៩៥០

Le talent = ការប៉ិន

Talentueux = ប៉ិន

Une notion = សញ្ញាណ

Notion préliminaire = បុព្វសញ្ញាណ

Le zèle = យតិភាព

La culture générale = សារពើវប្បធម៌

La culture intellectuelle = បញ្ញាវប្បធម៌

Un élève étourdi = សិស្សពោយឆាយ

Un élève distrait = សិស្សភាយមាយ

L'étourderie = សេចក្តីពោយឆាយ

La mémoire = សតិ, ស្មារតី, វិញ្ញាណក្ខន្ធ

Le mémoire = សារណា

L'imagination = មនោគតិ

ថ្ងៃ ២ ខែមិថុនា ឆ្នាំ ១៩៥០

(មានត)

រឿងព្រេងភូមា

# លោក សាង-សាវ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

## ៩ - ប្រុសមួយប្រពន្ធបី

"ស្រីណាស្មោះសរ សោមនស្សសាទរ មូលមិត្តស្នេហា
ប្ដីជនជីវិត ផ្គាប់ចិត្តភស្ដា ផ្សងតាមវាសនា ព្រេងពីនាយមក ។
បំរើស្វាមី ផ្ចិតផ្ចង់ស្មារតី ចិត្តគ្មានរលក ពេលមានទុក្ខផង
ត្រសងវិវេក កិច្ចកល់ជៀតជែក ឲ្យផុតទុក្ខគ្រោះ ។
ប្រុសណាបើបាន ស្រីកល្យាណ ដូចបានពោលនោះ
ត្រូវតែថ្នាក់ថ្នម ដោយកិច្ចសង្គ្រោះ កុំឲ្យមានមោះ ហ្មង
មួយដីក ។ ស្រីណាតាំងខុស គោរពជាតិប្រុស ដោយ
ខ្វាចគេថា បំរើស្វាមី គ្មានក្ដីជះថ្លា ស្រីនេះហៅមហា
កាឡកណ្ណី ។ ប្រុសឯប្រុសណា យកជាភរិយា នឹង
កើតអប្រិយ ជាមដល់អាត្មា ទុក្ខាក្រក្រី ត្រូវលះចោលខ្ចី
រកស្រីទៀតវិញ" ។

រឿងរ៉ាវក្រោយបង្អស់នេះ ដូចមានសេចក្ដីតំណាលថា កាលណោះ ក្នុងស្រុកកម្ពុត្យាមានលោកអភិជនម្នាក់ជាមហាសេដ្ឋី ។ មហាសេដ្ឋីនេះ

ដាច់ពូជពង្សវង្សត្រកូលអន្ទាយធ្លាយអំពីព្រះមហាក្សត្របន្តិចផង ប៉ុន្តែវត្ថុដទៃក្រៅអំពីទ្រព្យសម្បត្តិរបស់លោកគ្មានអ្វីជាសំខាន់ឡើយ ។ ឯរឿងដែលយើងនិទាននេះ មិនមែនរឿងរបស់លោកនុះទេ គឺជារឿងរបស់កូនលោកដែលបានដើរផ្សងព្រេងសំណាង; លោកអ្នកទាំងឡាយកាលបានមើលឬស្តាប់គង់ចាប់ចិត្តចាប់គំនិតពុំខាន ។

មានបុរសម្នាក់ជាកូនមហាសេដ្ឋីនៅស្រុកកម្ពុជា មាតាបិតាបានរៀបមង្គលការឲ្យមានភរិយាតាំងអំពីកាលនៅក្មេង តាមទំនៀមទម្លាប់ស្រុក ។ ក្នុងវេលារាត្រីស្ងាត់មួយ បុរសនេះមានសុបិននិមិត្តឃើញគេមកប្រាប់ថាខ្លួននឹងស្លាប់ដោយពស់ចឹក ។ ចាប់ដើមអំពីថ្ងៃដែលឃើញសុបិនមកបុរសនេះចេះតែមានបារម្ភទុក្ខព្រួយជានិច្ចកាល ដោយក្រែងខ្លួនស្លាប់ដូចយល់សប្តិនោះមែន ទើបនិយាយប្រាប់មាតាបិតានិងភរិយាថា “បើសិនណាខ្ញុំស្លាប់នឹងពស់វែកចឹកដូចខ្ញុំបានយល់សប្តិមែន ខ្ញុំសូមផ្តាំផ្តាច់ កុំធ្វើឈាបនកិច្ចរូបខ្ញុំ ឲ្យយកសពខ្ញុំទៅចងនៅលើក្បូនមួយ រួចបណ្តែតក្បូនតាមខ្សែទឹកទៅ” ។

ចំឡែកអស្ចារ្យណាស់ ករណីដែលបុរសនោះបានយល់សប្តិទាំងប៉ុន្មានក៏មានមែនគ្រប់ថ្នាក់គ្រប់ជាន់ ។ ថ្ងៃមួយនោះ អ្នកដើរកាត់ព្រៃស្រាប់តែពស់មួយចឹកដៃអ្នក, រួចក្នុងថ្ងៃនោះអ្នកក៏ទទួលមរណភាពទៅ ។

ឯនាងជាករិយាក៏គបានយករូបសពប្ដីទៅបូជាទេ នាងធ្វើតាមបណ្ដាំស្វាមី ។ នាងឲ្យគេយកខ្សែស្រែយ៉ាងល្អចងរូបនោះនៅលើក្បូនឫស្សីមួយហើយនាងបាចផ្កា បណ្ដែតក្បូននោះទៅ ទាំងមិនឲ្យអ្នកណាមួយអុំទូកតាមមើលឬទឹកនាអ្វីឡើយ ។ នាងបានធ្វើតាមពាក្យប្ដី នាងពេញចិត្តឥតរង្កៀស ។

ឯក្បូននោះអណ្ដែតទៅៗដោយស្រួលតាមទន្លេ ។ ដល់កន្លងទៅបានចំនួនច្រើនសប្ដាហៈ ក្បូននោះទៅដល់ប្រទេសមួយ ដែលមានគ្រូអាលម្ពាយម្នាក់យ៉ាងពូកែ ។ លោកគ្រូនេះមានកូនស្រីបីនាក់ ។ ក្នុងពេលដែលក្បូនអណ្ដែតទៅដល់មុខផ្ទះគ្រូនេះ នារីទាំងបីដើរទៅដល់មាត់ព្រែកបំរុងនឹងចុះទៅសំអាតសក់ដូចសព្វដង ។ នាងច្បងក្រឡេកពីលើមាត់ច្រាំងទៅឃើញក្បូន ហើយនិយាយទៅកាន់នាងប្អូនទាំងពីរថា "មើលនោះហ្ន៎! ក្បូនមួយអណ្ដែតចុះមក មានទាំងរូបបុគ្គលមួយផង" ។

នាងបន្ទាប់ឆ្លើយថា "មែនអ្នកបង! មើលហ្ន៎ដៃគាត់ហើមឡើងខ្លៅ, មនុស្សនេះមុខតែស្លាប់ដោយសារពស់ចឹកមិនខាន" ថាហើយនាងក៏យកឫស្សីមួយដែង ការទាញក្បូននោះបន្តិចម្ដងៗ មកជិតច្រាំង ។ ក្នុងពេលនោះ នាងពៅបំផុតខំស្ទៀកពាក់ប្រញាប់រត់ទៅហៅឪពុករបស់ខ្លួន ដែលជាគ្រូចេះមន្តអាលម្ពាយយ៉ាងឯកក្នុងដំបន់នោះ ។

ឯនំពុកនាងក៏មកដល់ភ្លាម ហើយយកថ្នាំពីក្នុងហិបយ៉ាងប្រញាប់ៗ លុះដាក់ថ្នាំរួចហើយ បុរសគ្មានកំរើករំពើកបន្តិចសោះ ៗ គ្រានោះក៏បណ្តេញកូនរបស់គាត់ទាំងអស់ឲ្យចៀសចេញឆ្ងាយអំពីទីនោះបន្តិច រួចគាត់តាំងសូត្រភាគមគាថាយ៉ាងអស្ចារ្យណាស់ ៗ មិនយូរប៉ុន្មានបុរសនោះបើកភ្នែកបន្តិចម្តងៗ ងាកមើលជុំវិញខ្លួនកាំងស្មារតី រួចដល់ដឹងខ្លួនមែនទែនក៏ក្រោកឡើង ហើយសាកសួរលោកគ្រូដែលបានជួយសង្គ្រោះជីវិតខ្លួន អំពីរឿងហេតុដែលមានមកទាំងប៉ុន្មាននេះ ៗ

ប៉ុន្តែដើម្បីនឹងពន្យល់ឲ្យបានច្បាស់ អំពីរឿងដែលមានតទៅមុខទៀតនោះ យើងគោងដំកបជាមុនថា បុរសនេះមានរូបឆោមលោមពណ៌ស្អាតល្អណាស់ កងស្តើង ភ្នែកខ្មៅរលោង ប្រកបសមសួនសុភាពបុរសា ៗ ឯគ្រឿងសំលៀកបំពាក់នឹងមាសពេជ្រ ដែលអ្នកពាក់ជាប់នឹងខ្លួនបង្ហាញឲ្យឃើញច្បាស់ថា អ្នកជាកូនចៅអ្នកមានពូជអំបូរខ្ពង់ខ្ពស់ក្នុងលោកិយនេះ ៗ លុះនាងទាំងបីដែលពួនពីក្រោយដើមអម្ពិលទឹកមួយធំនោះឃើញរូបបុរសល្អឥតខ្ចោះយ៉ាងនេះ ក៏ចាប់ចិត្តស្នេហាជាពន់ពេក ៗ, នាងទាំងបីនាក់នឹកក្នុងចិត្តថា នាងទើបតែបានជួយស្រោចស្រង់ជីវិតព្រះមហាក្សត្រមួយអង្គដែលគ្រងរាជ្យក្នុងអាណាចក្រមួយជិតៗ នោះ ៗ

ក្នុងពេលនោះ បងប្អូនទាំងបីនាក់ប្រកែកគ្នាដោយការគិតដូចមានតទៅនេះ :

នាងច្បងនិយាយថា "អញឃើញបុរសនេះមុនគេនៅលើក្បូន ត្រូវតែអញយកគាត់ធ្វើជាប្ដី" ។ នាងបន្ទាប់តបថា "ទេមិនត្រូវទេ; ខ្ញុំទេដែលត្រូវបានគាត់ ព្រោះថាខ្ញុំបានទំទាញក្បូន យ៉ាងត្រដេបត្រដាបមកដល់ច្រាំង បើអត់ពីខ្ញុំនោះគាត់មុខតែអណ្ដែតបាត់ទៅហើយ" ។ នាងពៅនិយាយថា "ទេនៅតែមិនត្រូវទៀត ខ្ញុំបានទៅហៅលោកឪពុកមក, ខ្ញុំបានជួយយោងជីវិតគាត់ ហេតុដូច្នេះ មានតែខ្ញុំមួយទេដែលត្រូវបានគាត់" ។

ឯការប្រកែកប្រណាំងរឿងនោះ ក៏ចេះតែវែងទៅៗ ។ ក្នុងពេលនោះ ឪពុករបស់នាងកំពុងនិយាយរៀបរាប់អំពីស្រុកទេសប្រាប់បុរស ។ ឯរូបទ្រង់ឫកពារបស់បុរសនេះពិតជាល្អមែនហើយ បានជានារីទាំងបីចាប់ចិត្តដល់ម្ល៉េះ ។ តើអ្នកណាមួយអាចមើលធ្លុះ? ចិត្តមនុស្សស្រីមិនងាយនឹងសំគាល់បានឡើយ ទោះតាំងពីណាមកក្ដី ទោះឥឡូវនេះក្ដី ។ ចិត្តមនុស្សស្រី គេទុកជាអណ្ដូងនៃសេចក្ដីពិតនិងសេចក្ដីមិនពិត ជាអណ្ដូងកុសលនិងអកុសល ជាអណ្ដូងនៃសេចក្ដីលោភនិងសេចក្ដីជួយដោះសគ្រោះ ជាអណ្ដូងនៃសេចក្ដីស្នេហានិងសេចក្ដីនិន្ទា ជាចិត្តប្រឡូកច្បាំងគ្នាក្នុងទីងងឹត; នៅពីលើអណ្ដូងនេះ មានទេពស្ត្រីមួយដែលចាំងក្ដីព្រោងព្រាយល្អអនេក នាំឲ្យកែវភ្នែកអ្នកមើលទាំងឡាយក្ដីរន្ទាលស្រវាំងវង្វេងអស់ ។

ក្រោយបន្តិចមក នាងច្បងដែលមានប្រាជ្ញាជាងគេ មានចិត្តអៀនខ្មាសនឹងការប្រឈ្លោះដណ្ដើមប្ដីគ្នានេះណាស់ ៗ មួយទៀតប្រហែលនាងខ្លាចក្រែងដល់ក្រោយទៅមិនល្អះនាងប្អូន ៗ ដែលនៅក្មេងជាងខ្លួន នាងក៏និយាយដោយបន្ទន់សំឡេងថា "នែប្អូន! យើងមានបងប្អូនតែបីនាក់ប៉ុណ្ណោះ, ពីដើមយើងស្រឡាញ់គ្នាណាស់ ៗ ឥឡូវយើងមិនគួរមកប្រឈ្លោះគ្នាដណ្ដើមប្រុសម្នាក់យ៉ាងដូច្នោះទេ ៗ ទោះបីប្រុសនោះជាស្ដេចសោយរាជ្យក៏ដោយ តោងយើងនឹកដល់ពាក្យដំបូន្មានចាស់ ហើយនាំគ្នាកុំរវល់ស្រឡាញ់បុរសនេះទាំងអស់គ្នាទៅ ៗ ឥឡូវនេះគេមានជីវិតឡើងវិញហើយដោយសារសិល្បសាស្ត្ររបស់ឪពុកយើង គួរណាស់តែយើងជួយគេឲ្យគេបានទៅដល់ផ្ទះសំបែងរបស់គេដោយស្រួល ហើយយ៉ាងរហ័សផង ៗ

នាងប្អូនទាំងពីរគិតមួយស្របក់ ក៏សុខចិត្តធ្វើតាមពាក្យនាងច្បង ហើយថែមទាំងបានសន្យាថានឹងជួយបុរសនោះឲ្យបានទៅដល់ផ្ទះវិញ ៗ នាងច្បងក៏ធ្វើឧបាយទៅនិយាយនឹងឪពុករបស់នាងថា សុំយកកម្រងផ្កាមួយយ៉ាងល្អទៅចងកឲ្យបុរសនោះ ៗ ក្នុងខណៈនោះនាងបន្លំយកខ្សែសូត្រមួយយ៉ាងចំឡែក ដែលឪពុកនាងលាក់ទុកក្នុងហិបទៅចងកឲ្យបុរសនោះ ៗ លុះកាលណានាងចងរួចស្រេចហើយ បុរសរូបស្អាតក៏ក្លាយខ្លួនក្លាយទៅជាសត្វសេកមួយយ៉ាងល្អពណ៌ខៀវលាយលឿង មានទាំងកន្ទុក

មួយ ពណ៌ផ្កាកុឡាបយ៉ាងស្រស់ផង ។ សត្វនេះទទះស្លាបមួយស្របក់ បន្ទិលខ្លួនហាក់ដូចជាសូមលាគេកល់គ្នា ហើយហើរកាត់តម្រង់ទៅស្រុកកំណើតរបស់ខ្លួនវិញ ។

សេកលុះហើរយូរទៅ ក៏បានទៅដល់សួនច្បារស្ដេចមួយ ហើយបានទំនៅលើមែកឈើដែលមានសន្លឹកជាច្រើននៅជិតស្រះមួយតូច ។ សត្វសេកបង់សម្រាកខ្លួននៅទីនោះចំនួនត្រឹមតែបីម៉ោងទេ ប៉ុន្តែដោយសារម្លប់ឈើត្រជាក់ល្អផង ដោយសារឃើញសត្វស្លាបឯទៀតច្រើនស៊ីផ្លែឈើយ៉ាងសប្បាយក្នុងទីសួននោះផង បក្សាក៏ភ្លេចនឹកនាដល់គោលបំណងនៃដំណើររបស់ខ្លួន ។ បក្សាក៏តាំងទីលំនៅ ។ ទីនោះយ៉ាងក្សេមក្សាន្តជាទីបំផុត ហើយលែងនឹកនាដល់បងប្អូនឪពុកម្ដាយប្រពន្ធកូនទាំងអស់ ដែលនឹកស្មានថាអ្នកស្លាប់បាត់បង់ជីវិតទៅហើយ ។

មានថ្ងៃមួយ នាយសួនច្បារបានយកកញ្ច្រែងដែលដាក់ផ្កានឹងផ្លែឈើទៅថ្វាយស្ដេច ។ ព្រះករុណាក៏ទ្រង់មានព្រះរាជឱង្ការថា "នៃនាយសួន! កាលពីមុន ផ្កានឹងផ្លែឈើដែលឯងយកមកឲ្យអញសុទ្ធតែល្អទាំងអស់ ចុះហេតុអ្វីបានជាឥឡូវនេះខុសពីដើមម្ល៉េះ អញឃើញប្លែកចំនួនពីរបីថ្ងៃមកហើយ ។

កណ្ឌទី ៣

# អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជវៃឆ្លាតបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

លីប៉ូស៊ុះប្រញាប់ទៅឱបនាងតៀវសៀនជាប់ហើយយំថា សេចក្ដីទៀងត្រង់សុចរិតនឹងសេចក្ដីស្នេហ៍ស្រឡាញ់របស់ប្អូននោះបងបានឃើញច្បាស់ណាស់ហើយ តែថាមានអកុសលមកជំទាស់ ទើបយើងមិនបានដឹងសុខទុក្ខគ្នា ។ នាងតៀវសៀនតបថា ទំរាំដែលនឹងខំទ្រាំទ្រនានខ្លួនក្នុងជាតិនេះ មានតែសេចក្ដីលំបាកព្រួយទ្រូងឡើងទៀត ព្រោះមានកម្មតាមមកទាន់ជាតិនេះបុណ្យរាសនាតិចណាស់ ទើបព្រាត់ប្រាសមិនឲ្យជួបគ្នាជាស្វាមីភរិយា នឹងរស់នៅថ្វីឲ្យវេទនាសូមលាអ្នកស្លាប់ហើយ ជាតិក្រោយសូមតាប់កំណើតឲ្យកើតមកជួបជាភរិយាអ្នក នឹងបានប្រណិបត៌ន៍ឲ្យអស់ចិត្តដែលស្រឡាញ់ ។ លីប៉ូឆ្លើយតបថា ប្អូននឹងមកធ្វើខ្លួនឲ្យ

ស្តាប់មុនឈឺនោះមិនគួរសោះ នាងចាំស្តាប់ពាក្យបងសិនចុះ កូនជាតិនេះ បើបងមិនបានខ្លួនប្អូនជាភរិយាទេ បងក៏មិនសូវនៅរស់ជាកូនប្រុសតទៅទៀត ៗ នាងតៀវសៀនតបថា តាំងពីខ្ញុំទ្រាំលំបាករៀងមកបាន ១ ខែហើយ អ្នកអើយទុក្ខក្នុងទ្រូងខ្ញុំតែត្រឹម ១ ថ្ងៃវិស័យដូចទុក្ខកន្លះឆ្នាំ បើភាណិតទ្រូងខ្ញុំឲ្យបាននៅរស់ធ្វើជាភរិយាអ្នក ត្រូវគិតដូចម្តេចឲ្យស្រេចដោយស្រួលទៅចុះ ៗ លីប៉ោឆ្លើយថា បងតាមតាំងតុះចូលទៅក្នុងវាំង ដល់មានឱកាសស្រួលបានជាត្រឡប់ចូលមករកប្អូន មិនបានប្រាប់តាំងតុះថាទៅណាទេ ឥឡូវនេះនៅបារម្ភក្រែងតាំងតុះរកមិនឃើញខឹងសង្ស័យ បើដូច្នេះបងសូមលាប្អូនទៅសិនចុះ ៗ នាងតៀវសៀនតបថា បើអ្នកខ្លាចអាសត្រូវកញ្ចាស់ហើយ អ្នកប្រហែលមិនបានឃើញមុខខ្ញុំទៀតឡើយ ៗ លីប៉ោឆ្លើយថា សូមឲ្យប្អូនបង្អង់បន្តិចចុះ ចាំឲ្យបងទៅត្រិះរិះគិតសិន ៗ នាងតៀវសៀនថ្លែងតបថា "ខ្ញុំបានឮគេក្តីឈ្មោះអ្នកល្បីល្បាញខ្លាំងណាស់ សូម្បីតែឈ្មោះក៏ដូចផ្គររន្ទះ ខ្ញុំឮឈ្មោះច្បាស់មានតែយកដៃខ្ទប់ត្រចៀកដកឃ ដោយការខ្លាចអំណាចលោក ព្រោះថាអ្នកខ្លាំងពូកែក្នុងការសង្គ្រាមនឹងរកអ្នកឯណាត្រឹមស្មើគ្មាន ឥឡូវខ្ញុំបានឃើញបានស្តាប់វាចារបស់អ្នកមិនសមដូចពាក្យឮសោះ បើនឹងពិគ្រោះមើលទៅឃើញថាអ្នកជាមនុស្សខ្លាច សូម្បីតែត្រឹមអំណាចតាំងតុះប៉ុណ្ណេះខ្លាចណាស់ទៅហើយ បើដូច្នេះហើយនឹងគិតការអ្វីបាន"

ថាហើយក៏ធ្វើជាខ្ញាយ៉ាះខ្វះងារដៃពីលីប៉ោចេញ ហើយស្ទុះទៅទីង លោតទឹកសម្លាប់ ៗ លីប៉ោទឹកភ្លូចចិត្តណាស់ បោះបោលខ្លួនចេញពីដៃ ហើយស្ទុះទៅឱបត្រកងនាងគៀវសៀនដាក់លើភ្លៅ ហើយនិយាយលួងលោមថាក់ថ្នមនាងជាយូរណាស់ ៗ

ចំណែកខាងតាំងតុះកាលដែលកំពុងអង្គុយគាល់ព្រះចៅហៀនតេនោះដល់គ្រឡេកមើលទៅគេលីប៉ោពុំឃើញក៏ពិតគាល់ក្នុងចិត្ត ៗ ទទួលស្តេចចូលទៅខាងក្នុង តាំងតុះឡើងជើស្ទូតមកផ្ទះជាប្រញាប់ស្រាប់តែឃើញសេះលីប៉ោចងទុកនៅមុខផ្ទះ ក៏លេះលោំងឡើងទៅដល់ទីដំណេកគ្រឡេកកេគនាងគៀវសៀនពុំឃើញ សួរពួកស្រីទាំងពួងៗ ដំរាបថានាងចុះទៅមើលសួនផ្កា ៗ តាំងតុះភ័យត្រាទឹកថា "ប្រហែលអាលីប៉ោទៅជួបគ្នាទេដឹង" ហើយប្រឹងចុះដើរទៅតាមមើលដល់សួនឧទ្យាន ៗ

ឯនាងគៀវសៀនបានគ្រឡេកទៅឃើញតាំងតុះចុះទៅដល់មាត់ទ្វារ ធ្វើជាមាយាស្ទុះទៅទីងលោតទឹកសម្លាប់ ៗ លីប៉ោក៏ស្ទុះទៅចាប់ឱបចាប់ពនាងឡើងមកវិញ, តាំងតុះដើរលឿនលេញទៅដល់ត្រែអង្គុយក្នុងសួនឃើញលីប៉ោឱបនាងគៀវសៀនខាប់ បេះប្រឡេះដៃចេញ. តាំងតុះនោះមិញក៏មានសេចក្តីក្តៅខ្លាំង ព្រោះមិនដឹងកលមាយាស្រីក៏ស្រែកខ្ទរខ្ទាំងថា ម៉ែអាលីប៉ោអាចោរក្បាលអាក្រក់ហ៊ានមកចក់លួចថើមអញ ៗ លីប៉ោងាកចេញមកមើលឃើញច្បាស់ជាតាំងតុះ ក៏ភ្ញាក់ខ្លួនដូចជាគេ

កន្ត្រាក់ ស្ទុះបោលខ្លួនដែលដាក់លើគ្រែម៉ឺម្មារត់ទៅ ។ តាំងគុះស្ទុះចាប់បានខ្លួននៅលើគ្រែ រៃរដេញតាមប្រកិតទៅផុតមាត់ទ្វារ ។ លីយូឃើញហើយក៏ស្ទុះទៅកំឯកប៉ះពារលើតាំងគុះ។ ដួលសន្លប់នៅទីនោះ ។ លីយូក៏ស្ទុះទៅក្រាហ៍លើកឡើងនាំទៅដាក់លើផ្ទះ, លុះដល់តាំងគុះដឹងស្មារតីសួរលីយូថា អ្នករត់មកមានការអ្វី? ។ លីយូឆ្លើយថាខ្ញុំបាទចេញតាមលោកមកពីគាល់ដល់ទ្វារផ្ទះ គិតទឹងលាលោកត្រឡប់ទៅវិញ ស្រាប់តែឃើញលីប៉ោរត់ចេញទៅស្រែកថា «មហាខបក់ដដេញកាប់សម្លាប់ហើយ» ខ្ញុំបាទរត់ចេញមកបង្ខឹងឃាត់លោក ទទួលលោករត់ចេញមកទង្គិចខឹង ខ្ញុំបាទដួលទៅ ខ្ញុំបាទសូមអភ័យទោសលោកចុះ ។ តាំងគុះនិយាយប្រាប់លីយូថា អាលីប៉ោនោះជាមនុស្សអកតញ្ញូណាស់, បង់កំឡាំងសោះដែលយើងចិញ្ចឹមវាជាបុត្រ គួរប្តូរមកលួចហុតឈាមយើង គឺវាមកលួចឱបក្រសោបនាងគៀវសៀនក្នុងវិស្សនផ្កា . យើងទឹងតាមសម្លាប់វាចេញទើបអស់សេចក្តីទោម្នេញក្នុងចិត្ត ។

លីយូឆ្លើយថា លោកខឹងសម្លាប់លីប៉ោចេញនោះមិនគួរទេ ខ្ញុំបាទសូមនាំសេចក្តីមកប្រៀបផ្ទូនលោកស្តាប់: កាលព្រះចៅឆសង់ឡេងផងដំណើងថា ស្តេចនគរ ១ មានកូនក្រមុំល្អណាស់បានបាត់ឲ្យគេចូលដណ្តឹង, ស្តេចនគរនោះមិនព្រមថ្វាយ, ព្រះចៅឆសង់អង្រឹងខ្ញាល់ ទើបប្រើចៅ-យ៉ែងទាហានឯកលើកពលទៅវាយយកស្រុកនោះបាន, ចៅយ៉ែងក៏នាំ

យកកូនក្រមុំនោះទៅថ្វាយព្រះចៅឧសង់អង់ៗ មានព្រះបន្ទូលទឹងទៀវ-
យ៉ងថា អ្នកទៅរកយកស្រុកឋានដឹងយកខាងនេះមកថ្វាយយើងៗ មិន
ត្រូវទឹងត្រេកអរទទួលយកទេ គួរតែអ្នកយកទុកធ្វើជាភរិយាចុះ ស្តេច
លើកនាងនោះឲ្យជាភរិយាទៀវយ៉ងតាមមានគុណបំណាច់ ទៀវយ៉ងមាន
សេចក្តីត្រេកអរគិតកតញ្ញូដល់ព្រះចៅឧសង់អង់; លុះយូរមកមានសឹក
លើកមកឡោមព័ទ្ធទីព្រះនគរជុំវិញ ស្តេចទ្រង់ព្រួយព្រះហឫទ័យខ្លាំង
ណាស់ ព្រោះគ្មាននរណាទឹងយកអាសាចេញច្បាំងទឹងបច្ចាមិត្របាន
ទៀវយ៉ងមានសេចក្តីភក្តីដល់ព្រះចៅផែនដីណាស់ ក៏ទទួលអាសាចេញ
ច្បាំងបង្ក្រាបសត្រូវបាន: ឯលីប៉ោជាទាហានឯករបស់លោក ហើយ
លោកទទួលចិញ្ចឹមជាបុត្រធម៌ពេញមុខ គួរតែលោកទំនុកបំរុងបំពេញ
ចិត្តលីប៉ោតាមប្រាថ្នា ដែលលោកនឹងមកទាំងខាស្រីម្នាក់ឲ្យខូចការជា
ប្រយោជន៍ដ៏ល្អតទៅមុខនោះមិនគួរសោះ ហេតុនេះខ្ញុំបាទសុំឲ្យលោក
លើកនាងតៀវសៀនឲ្យទៅធ្វើជាភរិយាលីប៉ោចុះទើបគួរ លីប៉ោនឹងមាន
ចិត្តភក្តីដល់លោក ៗ

តាំងតុះតបថា ដែលអ្នកថាទាំងនេះត្រូវណាស់ តែសុំបង្អង់ឲ្យយើង
ត្រិះរិះបន្តិចទៅសិន, លីយូក៏វិលត្រឡប់ទៅផ្ទះវិញ ៗ កាលតាំងតុះ
នឹងលីយូកំពុងនិយាយគ្នានោះ នាងតៀវសៀនមកលបស្តាប់ជាប់នៅ
ជញ្ជាំង លុះលីយូត្រឡប់ទៅហើយ តាំងតុះចូលទៅសួរនាងតៀវសៀន

ថា ឯងនឹងលីប៉ោសហាយនឹងគ្នាប៉ុះ ។ នាងគៀវសៀនឮដូច្នោះយំខ្សឹកខ្សួលហើយស្រែកឡើងជំរាបតាំងគុះថា កាលពីព្រឹកមិញនេះខ្ញុំម្ចាស់ចុះទៅបេះផ្កាក្នុងសួន មិនដឹងខ្លួនថាលីប៉ោលបចូលទៅរកខ្ញុំ ៗ ក៏ស្រែកឃើញលីប៉ោកាន់ខ្លួននៅផង ខ្ញុំម្ចាស់ភ័យណាស់ស្ទុះចៀសទៅ លីប៉ោតាមទៅជិតខ្ញុំម្ចាស់ហើយនិយាយថា ខ្ញុំជាកូនមហាឧបរាជ ខ្លួនអ្នកជាភរិយាមហាឧបរាជ នឹងខ្លាចខ្ញុំធ្វី ឈប់និយាយគ្នាសិន លីប៉ោក៏ស្ទុះទៅសង្កិនចាប់ខ្ញុំម្ចាស់ទាំងអំណាច ខ្ញុំម្ចាស់ដេរថាក៏វាមិនស្ដាប់ រិតតែឱបក្រសោបខ្លួនខ្ញុំម្ចាស់ ៗ ខឹងពេកណាស់ ស្ទុះទៅប្រាវត្តនឹងលោតទឹកសម្លាប់ វាស្ទុះទៅត្រកងចាប់ពខ្ញុំម្ចាស់មកវិញ ទទួលលោកអញ្ជើញទៅទាន់ កុំអីលីប៉ោវាធ្វើទុក្ខទោសខ្ញុំយ៉ាងណាមិនដឹង ខ្ញុំម្ចាស់នឹកខឹងណាស់ដែលលីប៉ោធ្វើឲ្យអាប់យសដូច្នេះ ។

តាំងគុះបានស្ដាប់ហើយឆ្លើយតបថា លីប៉ោនោះវាមានសេចក្ដីស្នេហ៍ស្រឡាញ់នាងខ្លាំងណាស់ យើងនឹងលើកនាងឲ្យជាភរិយាវាចុះ ។ នាងគៀវសៀនបានស្ដាប់ដូច្នោះ ក៏ត្រឡប់ធ្វើជាភ្ញាក់ខ្លួន ហើយក៏ក្រួនវិយោគសោកាថា "ខ្ញុំម្ចាស់ជាស្រីមានសេចក្ដីឧស្សាហ៍រក្សាកេរ្ដិ៍ឈ្មោះតាំងពីតូចមក ដល់លោកយកមកធ្វើជាភរិយា ទោះបីមិនពេញជាបឋមភរិយាក្ដីណា ក៏បាក់ដូចជាមាតាលីប៉ោប្រាកដ ដែលលោកនឹងលើកខ្ញុំម្ចាស់ឲ្យទៅជាភរិយាលីប៉ោជាបុត្រលោកវិញនោះ លោកនឹងឲ្យខ្ញុំទៅយកប៉ុរ

ព្រាវលោកក្រៅផ្ទះល្អជាងជាង   ខ្ញុំម្ចាស់មិនព្រមយកលីប៉ោសោះឡើយ ទេមាដូចលោកគួរប្រើគ្រោកហើយយកទឹកភ្នៅទៅលាបឲ្យខូចពណ៌សម្បុរទៅដូច្នោះ ខ្ញុំម្ចាស់មានសេចក្តីភាប់យសណាស់ ដែលនឹងបំរុងជីវិតឲ្យរស់នៅមើលមុខគេតទៅមិនបាន"   ថាហើយធ្វើជាក្រោកឡើងទាញយកគ្រឹះដែលនៅប្រហុនខ្នងនោះមកចំងការកសម្លាប់ ។ តាំងតុះស្ទុះទៅចាប់ដណ្តើមយកគ្រឹះពីដៃបាន ហើយលួងលោមថា ដែលបងថាទាំងនេះជាពាក្យចំអកឡកបញ្ឆោតលេងទេ ។ នាងតៀវសៀនទុនជប់ក្រាបទុបបាទជើងតាំងតុះហើយសោកាថា ការដែលកើតហេតុទាំងនេះក៏ព្រោះតែល័យូស្រឡាញ់លីប៉ោ"   ទើបនាំបង្កហេតុឲ្យលោកលើកខ្ញុំម្ចាស់ទៅធ្វើជាភរិយាលីប៉ោដូច្នេះ   ខ្ញុំឃើញថាល័យូមិនមែនស្រឡាញ់លោកដោយស្មោះត្រង់   ហើយមិនមែនករុណាខ្ញុំម្ចាស់សោះ ។ តាំងតុះតបថាដែលល័យូនិយាយដូចម្តេចៗនោះ   បងមិនបានជឿពាក្យវាទេ ។ នាងតៀវសៀនជំរាបថា   ខ្ញុំម្ចាស់ដែលនឹងនៅក្នុងវាំងនេះតទៅ គង់តែលីប៉ោនឹងមកធ្វើអន្តរាយដល់ខ្ញុំម្ចាស់ប្រាកដ   ខ្ញុំម្ចាស់ក៏គង់តែបានសេចក្តីអាស្រូវកាសខ្មាសគេជាងនេះទៅទៀត   ហេតុនេះសូមលោកអញ្ជើញទៅនៅឯមីគ្រុងថ្មី   ទើបបានខ្ញុំម្ចាស់អស់ភ័យបារម្ភតទៅ ។ តាំងតុះក៏យល់ឃើញត្រូវទើបនិយាយថា ចាំដល់ព្រឹកស្អែកសុំយើងលើកទៅ ។

លុះដល់វេលាព្រឹកឡើង ល័យូចូលទៅជំរាបតាំងតុះថា ថ្ងៃនេះល្អហើយ សុំឲ្យលោកលើកនាងតៀវសៀនឲ្យជាភរិយាលីប៉ោចុះ ។ តាំង

តុះតបថា លីប៉ោជាកូនចិញ្ចឹមរបស់យើង នាងគៀវសៀនជាភរិយានៃយើងដែរ បើនឹងលើកឲ្យធ្វើជាភរិយាលីប៉ោដូច្នោះ យើញខុសនឹងទំនៀមទម្លាប់បុរាណ ដែលលីប៉ោបានជាធ្វើល្មើសដល់នាងគៀវសៀនឲ្យមានសេចក្តីអៀនខ្មាស នោះយើងក៏លើកទោសទោលទៅហើយ ការណ៍នេះសុំឲ្យអ្នកទៅប្រាប់លីប៉ោចុះ ។ លីយូតបថា ដែលលោកមិនព្រមស្តាប់ពាក្យខ្ញុំបាទនោះ ការណ៍ដែលគិតទុកទាំងប៉ុន្មានគង់នឹងអន្តរធានព្រោះស្រីម្នាក់នេះ ។ តាំងតុះបានស្តាប់ក៏ខឹងខ្លាំងណាស់តបថា អ្នកនៅទទូចឲ្យយើងលើកភរិយាឲ្យលីប៉ោនោះ យើងមិនស្តាប់ពាក្យអ្នកទេ បើអ្នកមានចិត្តស្រឡាញ់លីប៉ោ ចូរអ្នកលើកភរិយារបស់អ្នកឲ្យលីប៉ោចុះ ពីថ្ងៃនេះតទៅកុំឲ្យនរណាយករឿងនេះមកនិយាយដដែលទៀត បើនរណាមិនស្តាប់យើងនឹងបង្គាប់ឲ្យកាត់ក្បាលចេញ ។ លីយូបានឮដូច្នោះក៏លាក្រោកដើរចេញទៅ ហើយនិយាយប្រាប់សេនាដែលចូលទៅរកតាំងតុះនោះថា “យើងទាំងឡាយនឹងបានសេចក្តីវិនាសអន្តរាយព្រោះមេគៀវ-សៀនម្នាក់នេះជាប្រាកដហើយ” និយាយហើយលីយូក៏ត្រឡប់ទៅផ្ទះ ។

ក្រោយនោះតាំងតុះឲ្យរៀបចាត់ចែងសេនាទាហាន ហើយនាំនាងគៀវសៀនឡើងរថទៅនៅក្រុងប៊្មី. បណ្តានាហ្មឺនសព្វមុខមន្ត្រីតូចធំក៏តាមជូនដំណើរតាំងតុះទៅដល់ទ្វារស្រុក. ឯនាងគៀវសៀនដែលអង្គុយលើរថ លុះក្រឡេកទៅឃើញលីប៉ោឈរនៅជាមួយនឹងពួកនាហ្មឺនក្បែរផ្លូវ

នាងក៏សំឡឹងមើលទៅប្រែងក្តុលីប៉ោធ្វើជាទុក្ខព្រួយសោក, លីប៉ោឃើញ
ផ្ទះធ្លាះកើតទោមនស្សក្រៅក្លាជាទុក្ខ ប្រឹងឈរមើលទាល់តែផុតកន្ទុយ
ភ្នែកហើយដកដង្ហើមធំ ។ អង់អ៊ុនឃើញលីប៉ោដើរចូលទៅចាប់ដៃហើយ
សួរថា មហាឧបាសកចេញទៅហើយ ខ្លួនអ្នកមានកង្វល់អ្វីបានជាមិនទៅ
តាម? ។ អង់អ៊ុននិយាយថា ខ្លួនខ្ញុំមិនស្រួលសប្បាយជាយូរថ្ងៃហើយ
ទើបបានជាខានមកជួបអ្នកនឹងមហាឧបាសក ថ្ងៃនេះព្រោះគេនិយាយថា មហា-
ឧបាសកទៅទៅនៅក្រុងជី ខ្ញុំខំប្រឹងមកដើម្បីជូនដំណើរលោក ឥឡូវឃើញ
ទឹកមុខអ្នកមិនសប្បាយ តើអ្នកមានសេចក្តីទុក្ខព្រួយពីការអ្វី? ។ លីប៉ោ
តបថា ដែលខ្ញុំមានសេចក្តីទុក្ខក្តៅក្រហាយទាំងម៉្លេះនេះ ពីព្រោះតែនាង
តៀវសៀនជាកូនលោក ។ អង់អ៊ុនភ្លេងសួរធ្វើបែបមិនដឹងថា មហា-
ឧបាសកមិនទាន់រៀបការនាងតៀវសៀនឲ្យអ្នកទេឬ? ។ លីប៉ោតបថា
រៀបការឯណា ហើយយកទៅទុកជាកិរិយាទៅហើយ ។ អង់អ៊ុនធ្វើ
ជាភ្ញាក់ស្រឡាំងកាំងហើយថា ដែលអ្នកនិយាយនេះខ្ញុំមិនទាន់ជឿផង
សោះ មហាឧបាសកនោះនឹងហានធ្វើដូច្នោះឬ? ។ លីប៉ោក៏នាំដំណើរតាំង
ពីដើមហេតុរបស់បុងឲ្យអង់អ៊ុនស្តាប់គ្រប់ប្រការ ។ អង់អ៊ុនស្តាប់ហើយ
ក៏ពោលទ្រហោះដែលហើយថា "ដែលមហាឧបាសកធ្វើដូច្នេះឧបមាដូចសត្វ
តិរច្ឆានពេកក្រៃណាស់ និយាយហើយក៏នាំលីប៉ោទៅផ្ទះ ឲ្យរៀបភោជ-
នាហារអញ្ជើញលីប៉ោបរិភោគផឹកស្រា, អង់អ៊ុននិយាយថា តាំងតុះធ្វើ

ការអាក្រក់ដល់កូនខ្ញុំដែលជាភរិយាអ្នក។ ទើបខ្ញុំក៏បានសេចក្ដីអាស្រូវគាស ខ្មាសគេណាស់ តែថាខ្លួនខ្ញុំនេះចាស់ជរាហើយ ជីវិតគង់នៅប៉ុន្មានថ្ងៃ ខ្ញុំគិតអាណិតតែខ្លួនអ្នកដែលនៅក្មេង ព្រោះសព្វថ្ងៃមានមនុស្សក្នុងព្រះនគរសរសើរពេបអានអ្នកថា មានថ្វីដៃខ្លាំងពូកែ ដែលតាំងគុះធ្វើអ្នកបាន ដូច្នេះ មនុស្សទាំងអស់គង់គ្នះតិះដៀលថា អ្នកជាមនុស្សល្ងង់ខ្លៅខ្លាចវិញ ។ លីប៉ោបានឮដូច្នោះខឹងណាស់ យកដៃទះគេបក្រហើយថា ដែលអាតាំងគុះរាធ្វើខ្ញុំដល់ទីនេះ ខ្ញុំត្រូវសងសឹករាឲ្យបាន ។ អង់អ៊ុនបានឮធ្វើជាយកដៃខ្ទប់មាត់លីប៉ោហើយឃាត់ហាមថា អ្នកកុំពោលពាក្យដូច្នោះ ក្រែងនាំខ្ញុំឲ្យខុសមានទោសទៅផង ។ លីប៉ោឆ្លើយថាខ្លួនខ្ញុំកើតមកជាប្រុសតែម្ដងសំគាល់ថា ខ្លួនមានថ្វីដៃខ្លាំងពូកែ មិនត្រូវនៅក្រោមបង្គាប់អ្នកណា ។ អង់អ៊ុនតបថា គំនិតបេះដូងនឹងថ្វីដៃនៃអ្នកនោះ មិនគួរនៅក្រោមអំណាចឲ្យតាំងគុះប្រើប្រាស់សោះ ឧបមាដូចជាកែវមានដម្លៃបានទៅដៃពានរកាន់ ។

លីប៉ោឆ្លើយថា ខ្ញុំមានសេចក្ដីតូចចិត្តពេក គិតនឹងសម្លាប់អាសត្រូវកញ្ចាស់ឲ្យបានជាង ១ វែងឆ្ងាយមកហើយ តែគិតពារែកសង្កត់ចិត្ត ព្រោះបានជាហៅរាជាបិតា បើនឹងសម្លាប់ចេញវេលាណា ខ្លាចគេគរហានិន្ទាបាន ។

ព្រះរាជពង្សាវតារប្រទេសកម្ពុជា

ភាគទី ២

សម័យឧដុង្គ

# អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តទៅ)

---

និយាយអំពីព្រះបាទបរមរាជាទី ៣ កាលទ្រង់ជ្រាបថាព្រះមហានគរធ្លាក់ទៅក្នុងកណ្ដាប់ដៃបច្ចាមិត្រហើយ ទ្រង់ក៏បង្អង់ការដែលនឹងត្រឡប់ព្រះនគរ ស្ដេចគង់នៅក្រុងស្រីអយុធ្យាជាមួយព្រះអាទិត្យវង្ស រហូតមកដល់ឆ្នាំ ព.ស. ១៦៣២ គ.ស. ១០៨៩ ក៏សោយទិវង្គតនៅទីនោះ ៗ រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទសទា-សិវបទ" ៗ ទ្រង់គ្មានព្រះរាជឱរសទទួលរាជសម្បត្តិស្នងព្រះអង្គទេ ៗ

កាលព្រះបាទជ័យវរ្ម័នទី ៦ ទ្រង់ជ្រាបដំណឹងថា ស្ដេចសោយទិវង្គតហើយ ក៏ត្រាស់ប្រើរាជបុរសជាច្រើននាក់ ព្រមដោយគជេន្ទ្រយានឲ្យទៅអញ្ជើញព្រះបរមអដ្ឋិ នឹងព្រះរាជនីជយរាជចូឆាមណីត្រឡប់ព្រះនគរវិញ ៗ

ចំណែកព្រះអាទិត្យវង្ស មហាឧបរាជ, កាលព្រះនាងជយរាជចូឆាមណី នឹងស្ដេចត្រឡប់ព្រះនគរ, បានក្រាបទូលសុំព្រះកែវមរកតទុកធ្វើសក្ការបូជា ៗ ព្រះនាងទ្រង់ទើសទាល់ព្រះហឫទ័យ ក៏ទ្រង់ព្រះរាជទាន

តាមសុំ ៗ ព្រះអាទិត្យវង្សទ្រង់អរណាស់ ទ្រង់ក៏ធ្វើពិធីសម្ពោធជាឧឡារិកអស់ការៈ ៧ ថ្ងៃ ៧ យប់ ៗ ព្រះកែវមរកតបានស្ដេចមកស្ថិតនៅក្នុងក្រុងស្រីយសោធរបុរៈ ពីក្នុងឆ្នាំ ព. ស. ១៥៩៦ ដល់ឆ្នាំ ១៦២៣ រួមជា ២៧ ឆ្នាំ ទើបស្ដេចទៅស្ថិតនៅក្រុងស្រីអយុធ្យានឹងក្រុងកំពែងពេជ្រ ដ៏ជាបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជា អស់កាលជាយូរឆ្នាំតមកទៀត ហើយទើបស្ដេចចេញផុតពីដែនខ្មែរ ទៅស្ថិតនៅទីដទៃ ដូចជានឹងមានអធិប្បាយតទៅខាងមុខ ៗ

## ព្រះបាទជយវរ្ម័នទី ៦

ព. ស. ១៦២៤-១៦៥០ គ. ស. ១០៨០-១១០៧

កាលព្រះបាទហសិវរ្ម័នទី ៣ ស្ដេចចេញចាកព្រះរាជធានីទៅគង់ឯក្រុងស្រីអយុធ្យាហើយ ព្រះរាជធានីក៏ចំហ គ្មានរាជការកាន់កាប់ដូចពោលហើយ ជាឱកាសឲ្យអ្នកលោកយសចបើងចង់ឡើងគ្រងរាជ-បល្ល័ង្កដែលទំនេរនោះ ៗ

ពិតដូច្នេះ ប្រាកដតាមប្រវត្តិសាស្ត្រថា ក្នុងគ្រានោះ មានបុរស ១ នាក់ដែលគេមិនស្គាល់ឈ្មោះនិងត្រកូល និងព្រាហ្មណ៍ ១ នាក់ទៀត ជាអ្នកលោភលាភយសហួសរាំសនា បានរួបរួមសេនារេហ៍ពលបានជាច្រើនហើយ ទៅតាំងទីសំណាក់នៅខាងជើងភ្នំដងរែក ដោយសញ្ញេតខាបម្រុងនឹងលើកមកលុកយកក្រុងស្រីយសោធរបុរៈ តែគ្រោះជាដោយ

វេលានោះ មានព្រះរាជវង្ស ១ អង្គព្រះនាមជយវ័ន្ទ កាលទ្រង់ជ្រាបករណីនេះហើយ ក៏ទ្រង់ស្រូតប្រមូលសេនាទាហានបានល្មមហើយក៏ស្ដេចលើកចូលទៅឈរកាន់កាប់ក្រុងស្រីយសោធរបុរៈបានមុនបច្ចាមិត្រ, លំដាប់នោះ ទ្រង់ក៏លើកទ័ពទៅកំចាត់អ្នកបះបោរនោះបង់ ហើយស្ដេចលើកទ័ពត្រឡប់ព្រះនគរ ហើយទ្រង់ក៏ចាប់ត្រួតត្រាការផែនដី តែទំនងនៅក្នុងឋានៈជាបណ្ដោះអាសន្ន ។

ស្ថានការណ៍នៃការគ្រប់គ្រងផែនដីក្នុងពេលនោះ នៅក្នុងផ្លូវចង្អៀតទីងដោះស្រាយ ដោយមានបញ្ហាថា គួរនឹងទៅក្រាបទូលអញ្ជើញព្រះបាទមហាសិរិវ័ន្ទទី ៣ ឲ្យស្ដេចមកគ្រងរាជសម្បត្តិវិញ ឬមួយនឹងអញ្ជើញព្រះជយវ័ន្ទឲ្យឡើងគ្រងរាជសម្បត្តិតែម្ដង ។ តាមយោបល់ភាគច្រើនថា ព្រះបាទមហាសិរិវ័ន្ទ ពិតមែនតែទ្រង់នៅក្នុងឋានៈជាព្រះរាជាម្ចាស់ផែនដី តែវេលានេះស្ដេចចេញទៅគង់នៅឯបច្ចន្តរដ្ឋទៅហើយតាំងទ្រង់ព្រះជរាទុព្វលភាពណាស់ទៅហើយផង តាំងទ្រង់ខ្សោយព្រះសមត្ថភាពៈណាស់ទៅហើយផង ពុំគួរនឹងស្ដេចត្រឡប់មកគ្រប់គ្រងផែនដី ក្នុងពេលដែលមានអាសន្នជាមហាទឹកនេះទេ គួរតែថ្វាយរាជសម្បត្តិទៅព្រះជយវ័ន្ទតែម្ដងទៅ ទើបអាចគ្រប់គ្រងផែនដីបាន ។

ដោយយោបល់នេះ រាជសម្បត្តិទើបបានទៅព្រះជយវ័ន្ទ ។ ទ្រង់ឲ្យប្រកាសធ្វើព្រះរាជពិធីបរមរាជាភិសេក ក្នុង ព. ស. ១៦២៤ នោះ ។

ក្នុងគ្រានោះ ប្រទេសកម្ពុជាមានព្រះរាជាជាម្ចាស់ផែនដីតែអង្គស្ងួន តែព្រះបាទហស៌វរ្ម័នទ្រង់អស់អំណាចទៅហើយ ។ ព្រះជយវរ្ម័នអង្គនេះជាឱរសទី ២ របស់ព្រះហិរណ្យវរ្ម័ន និងព្រះនាង ហិរណ្យលក្ស្មី ទ្រង់បានឡើងគ្រងពិភពដោយអំណាចកំឡាំងអាវុធ មានព្រះបរមនាមថាព្រះបាទជយវរ្ម័ន រាប់ជាទី ៦ ។ ស្ដេចគង់នៅក្រុងស្រីយសោធរបុរៈ, ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្ដេចមិនប្រាកដ, ព្រះរាជឱរសព្រះរាជធីតានោះទ្រង់គ្មានសោះទេ ។

ព្រះបាទជយវរ្ម័នទី ៦ នេះ ត្រូវរាប់ជាវង្សថ្មី, ព្រះរាជវង្សដែលជាអំបូររបស់ព្រះអង្គ បានទទួលតំណរាជសន្តតិវង្សមកជាច្រើនព្រះអង្គរាប់ដល់រជ្ជកាលព្រះបាទស្រីសូរ្យវរ្ម័នទី ២ ដែលសោយរាជ្យប្រមាណក្នុង ព. ស. ១៨៣៨ – ១៨៥០ ជាទីបំផុត ។

**ការផែនដី** ការគ្រប់គ្រងផែនដីក្នុងរជ្ជកាលនេះមិនប្រាកដថាបានចំរើនយ៉ាងណា ។ ការព្រះសាសនាទ្រង់រាប់អានលទ្ធិសៃវ៍ មានរាជ-បុរោហិតធំនាម "កម្រតេងអញគុរុ ស្រីទិវាករបណ្ឌិត" ជាទីប្រឹក្សាការផែនដី និង ធ្វើពិធីផ្សេង ៗ ថ្វាយ ។ ការព្រះសាសនាក៏មិនប្រាកដថាទ្រង់បានសាងអ្វីជាសំខាន់ទុកទេ ។

## និយាយពីជាតិថៃក្នុងប្រទេសខ្មែរ

ជាតិថៃ ឬ ហៅថា "សៀម" ជាជាតិមួយដែលដើមឡើយនៅក្នុងដែន

ហ៊ុនណាំ តែឥឡូវនេះ ទៅជាខេត្ត ១ របស់ចិន ។ ក្នុងវេងពុទ្ធសតវត្សទី ១៥ ទី ១៦ ត្រូវចិនលើកទ័ពមករុករានជាញឹកញយក៏បានប្រទេសទៅចិន ។ វេលានោះជនជាតិថៃភាគច្រើនទ្រាំនៅមិនបាន ក៏បោះបង់ស្រុកទេសរបស់ខ្លួននាំគ្នារត់សឹក ចុះមកអាស្រ័យនៅតាមជាយដែនប្រទេសកម្ពុជាភាគខាងលើ; ដោយចំពោះមានភាគច្រើនបានមកតាំងភូមិលំនៅ នៅត្រង់ខាងដើមទន្លេវិស្ណុដែលសៀមហៅថា "ម៉ែណាំចៅព្រះយ៉ា" នៅក្នុងអំណាចគ្រប់គ្រងរបស់រដ្ឋាភិបាលខ្មែរ, តែរដ្ឋាភិបាលខ្មែរ បានតាំងជាតិសៀមឲ្យជាមេគ្រប់គ្រងគ្នាផ្ទាល់ ដោយអន្លើ ៗ ទៅ ទំនងដូចជាតាំងមេចិនគ្រប់គ្រងពួកចិនក្នុងបច្ចុប្បន្ន ៗ ថៃនៅក្នុងអំណាចអារក្ខារបស់ខ្មែរ ដោយអាការយ៉ាងនេះមិនតិចជាង ៣០០ ឆ្នាំ ។

មកក្នុងសម័យ ១ ចាប់តាំងពីចុងរជ្ជកាលព្រះបាទហស៌វរ្ម័នទី ៣ ទៅទល់នឹងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ ប្រទេសកម្ពុជាមានការណ៍បះបោរចលាចលជាញឹកញយ ដោយក្សត្រិយ៍អ្នកគ្រងពិភពក្នុងសម័យនោះខ្សោយព្រះតេជានុភាព មិនអាចនឹងកម្រាបការបះបោរឲ្យរាបទាបទៅបានដោយងាយ ៗ មកក្នុងសម័យ ព.ស. ១៦៤០ ក្នុងចុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៦ ជាពេលដែលមានការបះបោរដូចពោលហើយ វេលានោះ មានបុរស ១ នាក់ជាតិសៀមឈ្មោះ ព្រហ្មកដ ជាបុត្រឈ្មោះ ពន្លកជ មានផ្តើមតាំងខ្លួនជាក្សត្រិយ៍គ្រប់គ្រងពួកថៃ នៅមណ្ឌល

យោធកងៀនសែនក្នុងខែត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ព្រះបាទជយវរ្ម័នទី ៦ ទ្រង់រវល់តែកម្រាបអសន្តិសុខខាងក្នុងព្រះនគរនិងការពាររាជបល្ល័ង្កឲ្យគង់នៅសិននោះ ទើបជាឱកាសឲ្យព្រះព្រហ្មរាជតាំងខ្លួនឡើងបាន ហេតុមកអស់វេលាជាច្រើនឆ្នាំ, ដល់ទៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ ទើបកម្រាបការបះបោរគ្រប់ទិសទាំងខាងក្នុង - ទាំងខាងក្រៅប្រទេសឲ្យរាបទាបទៅបាន ដូចជានឹងមានពោលជាថ្មីទៀតនៅខាងក្រោយ ។

ព្រះបាទជយវរ្ម័ន ទី ៦ ស្តេចសុគតនៅក្នុងរាជសម្បត្តិដល់ក្នុងឆ្នាំ ព.ស. ១៦៥០ ក៏សោយទិវង្គត រាជបណ្ឌិតថ្វាយព្រះនាម ព្រះបរមសពថា "ព្រះបាទបរមកៃវល្យបទ" ។

## ព្រះបាទ ធរណេន្ទ្រវរ្ម័នទី ១

ព.ស. ១៦៥០-១៦៥៦, គ.ស. ១១០៧-១១១៣

កាលព្រះបាទជយវរ្ម័នទី ៦ សោយទិវង្គតហើយ ព្រះអង្គគ្មានព្រះរាជឱរសនឹងទទួលរាជសម្បត្តិស្នងព្រះអង្គ, រាជបុរោហិតព្រមដោយគណៈសេនាបតី បានក្រាបទូលអញ្ជើញព្រះអង្គធរណេន្ទ្រវរ្ម័ន ដ៏ជាព្រះជេដ្ឋាធិរាជរបស់ព្រះបាទជយវរ្ម័នទី ៦ ដែលទ្រង់ព្រះជរាភាពណាស់ទៅហើយ នោះឲ្យឡើងគ្រងពិភពតមក, ក្នុងនាទដំបូងទ្រង់ប្រកែក ពុំព្រមទទួល, តែមកក្នុងទីបំផុត ដែលត្រូវទូលអង្វរណាស់ទៅ ក៏ទ្រង់ព្រមទទួលគ្រងរាជសម្បត្តិ ធ្វើពិធីបរមរាជាភិសេកនៅក្រុងស្រីយសោធរបុរៈ ។ (មាតា)

## សាវតារវត្តកំពង់ចាចជាភម

## នៅឃុំគោដ៏ ស្រុកកពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

## ព្រះវិន័យធរគណ ចៅអធិការវត្តនេះ រៀបរៀង

(រង្វាន់លេខ ៣)

---

ការណ៍ដែលនាំឲ្យកើតជាវត្តនេះឡើង អាស្រ័យហេតុ ២ ប្រការ·

១ – ដោយពួកឧបាសកឧបាសិកា នៅភូមិកំពង់ចាចិននេះមានចិត្តជ្រះថ្លានឹងព្រះពុទ្ធសាសនា ។

២ – ព្រោះភូមិនេះចាប់តាំងពីមានមនុស្សមកនៅ មិនទាន់មានវត្តសោះ សូម្បីទីដំណែលវត្តចាស់ៗបុរាណក៏គ្មាន ។ ពួកអ្នកស្រុកត្រូវការធ្វើបុណ្យទានម្ដងៗ គោនស្វែងទៅរកវត្តដទៃឆ្ងាយៗ ជាហេតុនាំឲ្យលំបាកក្នុងកិច្ចធ្វើបុណ្យទាន ។

អាស្រ័យហេតុនេះ ទើបចាស់ទុំក្នុងស្រុកបានប្រជុំគ្នាគិតកសាងវត្ត ។ បុព្វបុរសក្នុងសម័យនោះ ដែលជាអ្នកផ្ដើមកសាងឡើងជាដំបូង ចំនួន ១១ នាក់ គឺ តា-លិខ, តា-មាស, តា-ឡាយ, តា-គង់, តា-ព្រាប, តា-ម៉ាន់, តា-ជាន់, គេនករ ស្វា, ស្រីសុវង្ស ព្រំ, យសកេត្តិ សុខ, ដំរប់ ប្រាក់, ។ ឈ្មោះបុព្វបុរសទាំង ១១ នាក់នេះ បានទៅនិមន្តលោកគ្រូព្រះនាម "ពុត" ព្រមទាំងភិក្ខុបរិស័ទ ចំនួន ៣ អង្គ រួមជា ៤ អង្គពីភូមិក្រពើពុល ឃុំកំពង់ឆ្នាំង ស្រុករលាប្អៀរ

ខែត្រកំពង់ឆ្នាំង មកធ្វើជាចៅវត្ត ។ លោកគ្រូអង្គនេះ កាលដើមជាចៅអធិការវត្ត "ខិន" ក្នុងខែត្របាភ្នំ និមន្តមកក្នុងកាលបះស្នងស្ងួរ ពម កំហែង, មកនៅក្នុងភូមិក្រពើពុល, គង់ផែបណ្តែតទឹកជាទីសេនាសនៈ ។

កាលកសាងទីវត្តនេះ ( ជាដំបូងពីថ្ងៃ ៦ៗ៧ ឆ្នាំជូត សំរឹទ្ធិស័ក. ព. ស. ២៤០៥ ព្រះវស្សា គ. ស. ១៨៦២ ឆ្នាំ ក្នុងរាជ្យព្រះករុណា នរោត្តម ។

## ភូមិភាគផែនដីដែលកសាងវត្តនេះ

វត្តកំពង់បាចិននេះ កសាងលើទួលអំពីបុរាណ ១, ទួលនោះវែងបណ្តោយពីទិសទក្សិណទៅទិសឧត្តរ ហើយវែងតទៅទៀត ជួនដាច់ ជួនជាប់ដោយអន្លើ ៗ ។

(ទួលនេះតាមអាត្មាភាពយល់ថា មិនមែនជាមនុស្សលើកទេ គឺកើតឡើងដោយសង្ខារលោកតាក់តែង ។ ព្រោះថាជាច្រើនពាន់ឆ្នាំមកហើយ កាលទីដីទំនាបនេះ នៅជាទឹកទន្លេនៅឡើយ ទឹកជំនន់ទន្លេមេគង្គហូរនាំដីល្បប់មកចាក់បំពេញជានគរកម្ពុជានេះ ខ្សែទឹកហូរមកប៉ះនឹងភ្នំនាំឲ្យដីល្បប់សង្កកដោយអន្លើ ៗ តាមលំនាំខ្សែទឹក ព្រោះហេតុនេះបានជាទួលនោះច្រើនតែឃើញតភ្ជាប់ពីភ្នំមួយទៅភ្នំមួយ ។)

វត្តកំពង់បាចិននេះកសាងបែរមុខទៅទិសបូព៌ា; ទិសទក្សិណមានភ្នំកំពង់បាចិន ១ ចម្ងាយពីខែត្រវត្តចំនួន ១០០ ម៉ែត្រ ។ ភ្នំនេះតាម

បុកណាហៅថាភ្នំក្រពើ ព្រោះមានសណ្ឋានដូចរូបក្រពើ បែរក្បាលទៅ ខាងជើង, ទិសអគ្នេយ៍មានភ្នំនាងកង្រី – សម្ដេចនន – អកក្រពុំ(ឬអកពុំ), ទិសខាងកើតមានភ្នំសម្រោង, ទិសឦសានមានភ្នំត្រឡាល – ភ្នំទូកមាស, ទិសឧត្តរមានភ្នំបឹង - ភ្នំត្រង, ទិសបស្ចិមមានទន្លេអន្ទង់លត - បន្ទោលកី-ដីកំបុត ។

វត្តនេះដល់រដូវវស្សា ទឹកទន្លេឡើងលិចព័ទ្ធជុំវិញនៅតែទីទួលវត្ត ។ បើឆ្នាំណាទឹកធំម្ដង ៗ លិចទីវត្តទាំងមូល នៅសល់តែគល់ខឿនព្រះវិហារ ។

មុនដែលកសាងព្រះវិហារថ្មីនេះ ពួកឧបាសកនិងឧបាសិកា បានធ្វើសាលា ១ ប្រក់ស្បូវ សម្រាប់ប្រគេនលោកគ្រូចៅអធិការគង់ និងកុដិតូចៗ បីសម្រាប់ប្រគេនលោកបរិស័ទគង់ ។ ដល់មកឆ្នាំម្សាញ់ទើបលើកព្រះវិហារថ្មី ជាដំបូងនេះ កសាងជាបហើយស្រេច ។

កុងបុណ្យលោកគ្រូចៅអធិការទី ១ នេះមានហេតុ ១ ដែលគួរទាញមកអធិប្បាយដូចតទៅនេះ ។

សេចក្ដីថា: ខាងត្បូងកុដិលោក ចំក្បាលសំណឹង ចម្ងាយប្រមាណជា ៣ - ៤ ម៉ែត្រ មានដើមស្លកស្មោរ ១ ដើម ទំហំ ១ ឱប រិចរិលដោយអ្នកស្រុកស្មោះយកសម្បកធ្វើថ្នាំ ។ លោកឲ្យធ្វើរានទ ៣ ថ្នាក់តម្កល់ទុកក្រោមដើមឈើនោះ, ដល់ថ្ងៃសីល ឲ្យគេចែងយកភោជនាហារផ្សេងៗ មានទំ-ចេកជាដើមទៅដាក់បូជាលើរានទនោះ ។ ជួនកាលមានលេងភ្លេងផង តាមហេតុការណ៍ ១ ដង ១ កាល ។

ក្នុងសម័យមួយនោះ លោកគ្រូចៅអធិការ មិនសូវសប្បាយក្នុងព្រះអង្គ គ្រុនស្រៀវស្រាញ់ ជួនក្ដៅជួនត្រជាក់ជាយូរថ្ងៃ ៗ ពេលយប់មួយនោះ លោកនិមន្តទៅសឹង ស្រាប់តែយល់សប្តិឃើញហេតុផ្សេងៗ, ដល់ព្រឹកព្រហាមឡើង លោកប្រើមនុស្សឲ្យយកចបទៅជីកក្បែរគល់ស្តុកស្តោរ នោះជំរៅប្រមាណជា ៥-៦ តឹក ក៏ប៉ះលើថ្ម ១ ដុំធំ ជាហេតុនាំឲ្យផ្អើលអ៊ូអរដល់ភិក្ខុ-សាមណេរក្នុងវត្ត មកមើលជួយគាស់គាយលើកយកមកលើ ហើយឃើញរូបភាពបាក់បែកនៅលើថ្មនោះផង ៗ ក្នុងពេលនោះគ្មានអ្នកណាស្គាល់ថាជាថ្មអ្វីទេ នាំគ្នាហៅថា "ថ្មបល្ល័ង្ក" ៗ រួចលោកគ្រូចៅអធិការបង្គាប់ឲ្យសែងទៅដាក់ខាងក្រៅរបងវត្ត ខាងទិសឧត្តរ ៗ តាំងពីនោះមក ទៅជាមានបីសាចកាន់កាប់បាននាមបញ្ញត្តិជា "អ្នកតាយាយមាស" ដរាបសព្វថ្ងៃនេះ ៗ

ថ្មបល្ល័ង្កនោះយើងបានទៅពិនិត្យមើល គឺជាលិង្គព្រះឥសូរ ហើយរូបបាក់បែកនោះ គឺរូបព្រះនារាយណ៍ជិះគ្រុឌ ៗ លិង្គនេះទទឹង ០ម. ៨៥ បណ្ដោយ ០ម, ៩០ កំពស់ ០ម. ៧៤ ហើយសព្វថ្ងៃនេះ ប្រេះឆាបាក់បែកជាច្រើនអន្លើ ៗ

វត្តនេះកើតឡើង ក្នុងសម័យខ្មែរយើងកាន់ព្រហ្មញ្ញសាសនា ៗ រឿងនេះមុខគួរឲ្យសង្ស័យ ព្រោះយើងបានសួរមនុស្សចាស់ៗ អាយុរាង

៨០ ប្លាយឆ្នាំមកហើយថា ភូមិកំពង់ចាចិននេះ ដែលមានមនុស្សមកនៅប្រហែលប៉ុន្មានឆ្នាំហើយ? ។ គាត់ទាំងនោះឆ្លើយថា មិនយូរប៉ុន្មានទេ គឺមានមនុស្សមកនៅមុនគេសាងវត្ត ប្រមាណជា ២០ ប្លាយឆ្នាំ ឬ ៣០ ឆ្នាំ យ៉ាងយូរ ព្រោះកំពង់នេះពីដើមជាកន្លែងអ្នកស្រុក ភូមិខាងកើតគេបតទូក គេឲ្យឈ្មោះកំពង់នេះថា កំពង់បស្ទិម (ក្រោយមកជាកំពង់ចាចិន) ។ គួរឆ្ងល់ បើទើបនឹងមានមនុស្សមកនៅប្រមាណជាង ១០០ ឆ្នាំទេ ហេតុម្ដេចក៏មានសិវលិង្គនេះកប់ក្នុងដីជំរៅដល់ម៉្លោះ ។ (តាមយើងយល់ថា កន្លែងនេះជាភូមិចាស់ កាលសម័យព្រេងនាយមានមនុស្សមកនៅម្ដង ហើយលះបង់ចោលទីនេះទៅវិញជាច្រើនរយឆ្នាំ បាត់ស្នាមអ្នកដឹងអ្នកយល់អស់ទៅ ហើយព្រៃដុះដេរដាសពាសពេញឡើង គ្រាក្រោយទើបមានមនុស្សមកនៅជាថ្មីទៀតដរាបមកដល់សព្វថ្ងៃនេះ ។)

លោកគ្រូចៅអធិការទី ១ នោះ កាលនិមន្តមកគង់ជាដំបូង ព្រះជន្ម ៦០ ឆ្នាំ លុះដល់ព្រះជន្ម ៨០ ឆ្នាំទើបលោកសុគត. ។

ដល់ឆ្នាំជូតបញ្ចស័ក ព.ស. ២៤៣០ លោកគ្រូព្រះនាម "កែវ" ធ្វើជាចៅអធិការ ទី ២ តមកទៀត លោកគង់បាន៧វស្សាចាកសិក្ខាបទ ។

ដល់ឆ្នាំមមែធស័ក ព.ស. ២៤៣៨ លោកគ្រូព្រះនាម "ឌៀប" ធ្វើជាចៅអធិការទី ៣ តមកទៀត លោកគង់បាន ២៦ វស្សាព្រះជន្មគំរប់ ៩១ ឆ្នាំ, លុះដល់ថ្ងៃ ៦ រោចខែអស្សុជ ឆ្នាំរកាស័ក ព.ស. ២៤៦៣ គ.ស. ១៩២០ លោកសុគត ។ (មានត)

## ប្រវត្តិរបស់អេសុប

# លោក ផេង-ជ្រឹ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យតារីភ្នំពេញ

ប្រែពីបារាំងមកជាខ្មែរ

(តទក)

---

អេសុបឆ្លើយថា "ទុំរមើលចុះប្រផ្លូចំជាមេកុហកយ៉ាងធំ ខ្ញុំអញដែលបានឃើញអន្ទូបពីរបែរជាត្រូវពាក់; ចំណែកព្រះតេជព្រះគុណ លោកបានឃើញតែមួយ លោកត្រឡប់ជាមានលាភ គឺមានគេមកអញ្ជើញទៅពីសាលៀង" ។ សន្ធុះឮសំដីត្រូវ ក៏ពេញចិត្តស្តាប់បាន ហើយប្រាប់ឲ្យមនុស្សឈប់វាយលោក តែមិនទាន់ឲ្យចេញពេលនេះទេ ·គឺចាំពេលក្រោយទៅទៀត ។

ថ្ងៃមួយ សន្ធុះនឹងអេសុបទាំគ្នាដើរលេងមើលសិលាចារឹក នៅឯប្រាសាទបុកណាដោយសេចក្ដីសប្បាយ ។ មានសិលាចារឹកមួយកន្លែងចៅហ្វាយរបស់លោកពិនិត្យមើលយូរណាស់ តែមិនយល់សេចក្ដីសោះ ។ អក្សរក្នុងសិលាចារឹកនោះគេដាក់សុទ្ធតែអាទិសង្កេត ។ ចៅហ្វាយនិយាយចំពោះមុខបាវថា ខ្ញុំមើលចារឹកហ្នឹងមិនយល់ទេ ។ អេសុបសួរទៅចៅហ្វាយរបស់លោកថា: "បើខ្ញុំបានប្រាប់កំណប់ទ្រព្យដល់លោក តើលោកឲ្យអ្វីដល់ខ្ញុំបាទ ?" ។ សន្ធុះឆ្លើយថា: "អញបើកឯងឲ្យចេញជាអ្នកជាហើយចែកកំណប់ឲ្យពាក់កណ្ដាលថែមទៀត" ។ អេសុបប្រាប់ថា: "សិលាចារឹកនេះបានសេចក្ដីដូច្នេះ គឺដើរចេញពីគោលចារឹក

៤ ជំហាន នឹងប្រទះកំណប់ទ្រព្យមួយ" ។ លុះគេជីកទៅក៏ឃើញកំណប់មែន ។ សង្ឃុះនៅចាំពាក្យដែលខ្លួនសន្យាដែរ តែលោកពុំបានព្រមឲ្យអេសុបចេញ ហើយមានវាចាថា "ព្រះជាម្ចាស់ឃាត់អញថាកុំអាលឲ្យឯងចេញ ទាល់តែឯងបង្ហាញចារឹកដល់អញទៀត ព្រោះក្នុងអក្សរនៃសិលាចារឹកដូចជាប្រាប់ថា នៅមានកំណប់មួយមានដំឡៃជាងមុនទៅទៀត" ។ អេសុបប្រាប់ថា "តាមចារឹកវាងនេះ គឺបានសេចក្ដីថា ថយ ៥ ជំហានទៅទៀតគេនឹងប្រទះកំណប់មួយទៀត" ។ លុះគេថយតាមសេចក្ដីដែលបង្គាប់ហើយជីកទៅ គេឃើញកំណប់មួយទៀតមែន ។ ចៅហ្វាយរបស់លោកឃើញគម្រិះនៃលោកពូកែដូច្នេះក៏មានវាចាថា: "ឯងមានប្រយោជន៍ដល់អញណាស់ កុំសង្ឃឹមថាអញបើកឲ្យឯងឡើយ" ។ អេសុបឆ្លើយថា: "បើលោកមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទៅក្រាបបង្គំទូលដល់ព្រះករុណាព្រះនាមដឺនិះ (Denis) ព្រោះក្នុងសិលាចារឹកនោះមានសេចក្ដីប្រែគ្នាថា "កំណប់នេះជាកំណប់របស់ព្រះអង្គ" ។ សង្ឃុះភ័យក៏អង្វរថា: "ចាំអញឲ្យចំណែកដល់ឯង ចូរឯងអាណិតតែកុំមាត់ចុះ" ។ អេសុបឆ្លើយឡើងទៀតថា "មិនចាំបាច់លោកមានប្រសាសន៍ថាចែកឲ្យដល់ខ្ញុំទេ ក្នុងចារឹកនោះមានសេចក្ដីទៀតថា: ត្រូវតែលោកចែកឲ្យខ្ញុំ" ។ លុះវិលត្រឡប់ទៅដល់ផ្ទះ សង្ឃុះឲ្យគេយកអេសុបទៅដាក់ប្រគុំក់ជើងទុកក្នុងផ្ទះមួយដាច់តែឯង ខ្លាចក្រែងលោកដើរទៅបរិហារប្រាប់អ្នកដទៃ ។

លោកស្រែកថា : " ហ្នឹងហើយ ។ ដែលលោកអ្នកប្រាជ្ញត្រូវចាំពាក្យសន្យា ? តែណ្ហើយចុះ អោះបីលោកធ្វើយ៉ាងដូចម្ដេចក៏ដោយ អាណិតតែៈលោកបើកឲ្យខ្ញុំទៅជាអ្នកជា " ។

ទំនាយរបស់អេសុបត្រូវប្រាកដ ។ ហេតុដ៏អស្ចារ្យមួយដែលកើតឡើងធ្វើឲ្យប្រជារាស្ត្រក្នុងប្រទេសសាមូសមានសេចក្ដីព្រួយច្រើន ។ មានសត្វក្អែកមួយឆាបយកក្រវិលដែកមួយ ក្រវិលនេះមានសណ្ឋានដូចជាត្រាដែលសម្រាប់បោះលើសេចក្ដីជំនុំរបស់ក្រុមរដ្ឋមន្ត្រី ហើយទំលាក់ចុះលើទ្រូងនៃមនុស្សជាខ្ញុំបំរើម្នាក់ ។ មហាជនទៅប្រឹក្សាការណ៍នេះជាមួយនឹងលោកសង្ឃ ដែលជាអ្នកប្រាជ្ញមួយក្នុងនគរផង ជាទីប្រឹក្សាក្នុងព្រះរាជអាណាចក្រផង ។ លោកនេះ សូមឱកាសអំពីគេកល់គ្នាថាចាំយករឿងនេះមកពិចារណាមើល ហើយក៏ទៅរកតែតម្រាមួយដដែលឲ្យជួយគឺអេសុប ។ លោកប្រាប់សង្ឃថា " សូមឲ្យនាំលោកទៅឯកណ្ដាលមហាជន ព្រោះថាបើកាលណាខ្ញុំឆ្លើយទៅ ហើយត្រូវ កេរ្តិ៍ឈ្មោះក៏គង់ធ្លាក់ទៅលើលោក, បើកាលណាខ្ញុំឆ្លើយទៅ ហើយមិនត្រូវសមប្រកប នោះមានខ្លួនខ្ញុំស្រាប់ដែលត្រូវគេគ្រះគិះដៀល ។ សង្ឃយល់ព្រមហើយនាំលោកឡើងកាន់ទីវេទិកា ដែលសង់សម្រាប់ជំនុំប្រឹក្សានូវរឿងក្រវិលទាន់លើ ។ គ្រាន់តែឃើញអេសុបឡើងទៅ គេនាំគ្នាសើចហើយនិយាយស្នានថា " មនុស្សដែលមានរូបរាងបែបហ្នឹងមិនសមនឹងមានប្រាជ្ញាអាប

ដោះប្រស្នានេះបានឡើយ" ។ លោកឆ្លើយតបថា "សូមអស់លោកកុំសំគាល់តែពណ៌ខាងក្រៅ សូមគិតដល់រសជាតិទឹកដែលមាននៅខាងក្នុង" ។ អ្នកនគរទាំងឡាយស្រែកឡើងថា "បើដូច្នោះ ចូរឯងនិយាយចុះ កុំគោតញេញើតអ្វីនូវរឿងអស្ចារ្យនេះ" ។ អេសុបឆ្លើយថា "សូមទោស! ខ្ញុំបាទមិនទាន់ហ៊ានអធិប្បាយទេ ព្រោះនឹងមានការទាស់គ្នាអំពីជ័យជំនះនឹងកើត ឈ្មោះរលង់នាយចៅហ្វាយហើយនឹងបាត់ គឺខ្លួនខ្ញុំបាទនេះឯង បើកាលណាខ្ញុំបាទនិយាយខុស គេនឹងវាយខ្លួនខ្ញុំបាទ បើកាលណានិយាយទៅហើយត្រូវជាងនាយចៅហ្វាយ ខ្ញុំបាទក៏គង់ត្រូវរំពាត់ទៀត" ។ អ្នកនគរឮសំដីដូច្នេះ ក៏បង្ខំសង្ទុះឲ្យបើកអេសុបលែងទៅជាអ្នកជា ។ សង្ទុះមិនព្រម ។ ទីបំផុតមានសេនាបតីយ៉ាងធំម្នាក់មានវាចាថា "ត្រូវតែអ្នកឯងបើកគេលែង បើនឹងទទឹងមិនបាន" ។ សង្ទុះទាល់ប្រាជ្ញក៏សុខចិត្តព្រមតាមសំដីរបស់លោកសេនាបតី ។ អេសុបតាំងនិយាយឡើងថា "តាមហេតុកេតនេះ គឺនឹងមាននគរប៉ះទេសបំរុងចង់យកយើងធ្វើជាអ្នកបំរើរបស់គេ សត្វខ្លែងគឺស្តេចមានអំណាច" ។

លុះកាលកន្លងមកមិនយូរប៉ុន្មាន ព្រះរាជាព្រះនាមក្រេស៊ុះ (Krésus) ជាស្តេចសោយរាជ្យក្នុងដែនលីឌី (Lydée) មានបណ្តាំមកថា "ត្រូវឲ្យអ្នកនគរសាមូសនាំពកសួយសារទៅថ្វាយចំពោះព្រះអង្គ បើមិនយល់ព្រមតាមទេ ទ្រង់នឹងបញ្ជូនកងទ័ពមកកំហែងបង្ខំជាមិនខាន" ។ មានមនុស្ស

ទាំងឡាយគាត់ច្រើនយល់ព្រមថាត្រូវចំណុះគេទៅ ។ តែអេសុបនិយាយប្រាប់ថា "ភាពរបស់ពិភពលោកមានតែផ្លូវពីរៈ ទី ១ ឯករាជ្យមុនដំបូងពិបាកណាស់ឈឺខ្លួន តែសុខសប្បាយក្នុងមុខស្រួលចិត្តក្នុងពេលក្រោយ, ទី ២ ភាវៈជាអ្នកខ្ញុំគេងាយស្រួលដំបូង តែត្រូវពិបាកវេទនាចុងក្រោយ" ។ អេសុបគឺជាអ្នកប្រដៅឲ្យដំបូន្មានពេញដោយបញ្ញា គួរសមល្មមឲ្យប្រទេសសាមូសអាចការពារខ្លួនឯករាជ្យរបស់ខ្លួនបាន ។ បណ្ដាជនបានស្ដាប់សំដីត្រូវដូច្នេះ ក៏នាំគ្នាបណ្ដេញរាជទូតរបស់ព្រះបាទក្រេស៊ុះ ឲ្យចេញពីព្រះនគរសាមូស ។

ព្រះបាទក្រេស៊ុះរៀបពលត្រៀម បំរុងនឹងលើកទៅវាយប្រទេសសាមូស ។ រាជទូតបានក្រាបបង្គំទូលថាៈ "រៀងវាយដែនសាមូសសូមទ្រង់ឈប់បង្អង់សិន ព្រោះក្នុងដែននោះមានមនុស្សម្នាក់ឈ្មោះអេសុប បើអ្នកនេះនៅក្នុងសាមូសដរាបណា យើងមិនងាយនឹងវាយបែកដរាបនោះ ដ្បិតប្រជារាស្ដ្រទាំងឡាយក្នុងស្រុក តែងជឿស្ដាប់ពាក្យនៃអេសុបនោះពេក" ។ ព្រះបាទក្រេស៊ុះបញ្ជូនរាជសារមួយមកកាន់សាមូសដោយមានពាក្យសន្យាថា "បើព្រមប្រគល់ថ្វាយអេសុបដល់ព្រះអង្គ នោះទើបទ្រង់ទុកឯករាជ្យឲ្យជាសេរី" ។ ពួករដ្ឋមន្ត្រីឃើញការណ៍នេះស្រួល ហើយមិនគិតស្មានថាការណ៍ដែលខ្លួនកល់រូបបានសុខសាន្តដោយសារមានលោកនៅជាមួយឡើយ ។ អេសុបដឹងដំណឹងដូច្នោះក៏

ពាក្យស្លូតរបស់ពួកនាម៉ឺនទាំងនោះដោយសេចក្ដីប្រមាថមួយថាៈ “ឆ្កែចចកទាំង ពួកពពែទាំងឡាយ បានព្រមចុះកិច្ចសន្យាធ្វើសន្តិភាពជាមួយគ្នា តែ ប្រាប់ឲ្យពួកពពែទាំងឡាយដេញឆ្កែស្រុកទាំងឡាយចេញ ; លុះពពែ ទាំងឡាយគ្មានអ្នកណាការពារ ឆ្កែចចកមកចាំស៊ីដោយស្រណុក គ្មាន ពិបាកដូចលើកមុន” ។

ពួកមនុស្សក្នុងសាមូសយល់ព្រមតាមយោបល់របស់អេសុប ។ ប៉ុន្តែ ទោះអ្នកស្រុកយល់ព្រមតាមដូច្នោះក៏ដោយ លោកនៅតែមានបំណងចង់ ទៅជួបព្រះចៅក្រេស៊ុះ តែលោកប្រាប់អ្នកស្រុកសាមូសថាៈ “ពិតមែន តែខ្ញុំទៅនៅខាងព្រះចៅក្រេស៊ុះ គង់តែខ្ញុំគិតជួយអ្នកពលគ្នាឲ្យបាន សម្រេចនូវផលល្អ ដូចជាខ្លួនរបស់ខ្ញុំនៅឯនគរសាមូសដែរ” ។

ព្រះចៅក្រេស៊ុះ លុះទតឃើញអេសុបកាលណា ទឹកធ្លល់ក្នុងព្រះរាជហឫទ័យថា “មនុស្សបែបហ្នឹងមិនគួរឡើយហ៊ានមកជំទាស់ដល់កិច្ចការ របស់អញសោះ ហើយទ្រង់ទ្វាល់ស្រែកថាៈ យើ ! អាហ្នឹងហើយឬ ដែលធ្វើទើសទទែងដល់ការរបស់អញ” ។ អេសុបចូលទៅជិតក្បែរ ព្រះបាទទាំងពីរនៃព្រះរាជា ហើយនិយាយក្រាបទូលថាៈ “សូមទ្រង់ ព្រះមេត្តាប្រោស ! មនុស្សម្នាក់ដែលចង់ចាប់សត្វកណ្ដូប ក៏ទៅបេះ ឯសត្វវិញ ហើយគិតនឹងសម្លាប់សត្វដូចជាសត្វកណ្ដូបដែរ ឯសត្វ អង្វរមនុស្សនោះថាៈ ខ្ញុំគ្មានបានធ្វើអ្វីដល់អ្នកទេ ៈ គ្មានកាត់ស្រូវ គ្មានបំផ្លាញដំណាំអ្វីរបស់អ្នកឡើយ ខ្ញុំមានតែសំឡេងដែលអ្នកឮខ្ញុំច្រៀង

គ្មានប្រកបដោយទោស; បពិត្រមហារាជ! ទូលព្រះបង្គំជាខ្ញុំក៏ដូចជាសត្វរនោះដែរ គឺមានតែសំដី, ហើយសំដីហ្នឹងទៀត ក៏មិនមែននិយាយសម្រាប់ប្រមាថមើលងាយដល់ព្រះកិត្តិយសរបស់ព្រះអង្គឡើយ ។ ព្រះចៅក្រេស៊ុះដែលបានទ្រង់ព្រះសណ្ដាប់នូវវាចាដូច្នោះហើយ ក៏សរសើរនូវបញ្ញាដ៏វៀងវៃ ទឹងមានព្រះរាជហឫទ័យអាណិតពន់ពេក មិនត្រឹមតែប្រទានទោសដល់អេសុបទេ ព្រះអង្គថែមទាំងឈប់រករឿងហេតុនឹងប្រជារាស្ត្រនៃនគរសាមូសផងទៀត ។

ក្នុងវេលានោះ អេសុបចាប់ធ្វើនូវសុភាសិតទាំងឡាយជាពាក្យកាព្យ ហើយទុកថ្វាយចំពោះព្រះចៅក្រេស៊ុះ, ចំណែកលោកក៏វិលទៅកាន់សា-មូសវិញ ។ ពួកនាម៉ឺនជំនួបព្រមទាំងប្រជារាស្ត្ររៀបទទួលលោកជាឧ-ឡារិក ។ រួចលោកមានបំណងនឹងធ្វើដំណើរទៅកាន់ប្រទេសក្រៅផ្សេងៗ ដើម្បីរកវៀននូវវិជ្ជាថែមទៀត ជាមួយនឹងមនុស្សទាំងឡាយដែលមាននាមហៅថា "បណ្ឌិត" ។ ខាងក្រោយបំផុត លោកទៅអាស្រ័យនឹងព្រះរាជាព្រះនាមលីសេរុះ (Lycérus) ដែលសោយរាជ្យក្នុងនគរបាប៊ីឡូន ។ ក្នុងសម័យនោះ ព្រះរាជាទាំងឡាយចូលចិត្តលេងចំណោទណាស់ បើនគរណារកមិនឃើញ នគរនោះត្រូវនាំសួយសារអាករទៅថ្វាយចំពោះព្រះរាជាដែលជាដៃគូ ឬមួយគេយកជាច្បាក់ ។ ចំណែកព្រះករុណាលីសេរុះដែលមានអេសុបនៅជាមួយច្រើនមានជ័យ ល្បីកេរ្តិ៍ឈ្មោះអំពីការដោះស្រាយប្រស្នាឬចោទឲ្យគេរក ។ (មានត)

## លោក វ៉ាយ-ប៊ុក ក្រុមការនៅពុទ្ធសាសនបណ្ឌិត្យ

### ប្រែរៀបរៀង

(តមក)

តែព្រះសិទ្ធត្ថបានតបទៅព្រះបាទពិម្ពិសារថា: "ព្រះករុណាថ្លៃវិសេស! របស់ទាំងអស់នោះទូលព្រះបង្គំមានហើយ, ទូលព្រះបង្គំបានលះបង់ ដើម្បីនឹងស្វែងរកធម៌ពិត, ទូលព្រះបង្គំបានចំរកហើយនឹងរកតទៅអនាគតទៀត, បើទុកណាជាប្រាសាទសក្កៈ (សក្កទេវរាជ: ព្រះឥន្ទ្រាធិរាជ), បើកទ្វារចាំហ ហើយក៏ពពួកទេវតាមកអង្វរឲ្យទូលព្រះបង្គំចូលទៅក្នុងមហាប្រាសាទនោះ ទូលបង្គំក៏មិនព្រមចូលទៅដែរ, ទូលបង្គំមានបំណងនឹងស្ដាបនាព្រះរាជអាណាចក្រនៃច្បាប់; ទូលបង្គំនឹងទៅឯប្រទេសគយា ដែលមានរុក្ខជាតមានសន្ទឹកត្រសុំសាខា មានម្លប់ត្រជាក់ស្រួលនៅទីនោះ, ប្រហែលទូលបង្គំអាចរកពន្លឺដែលជាធម៌ពិតឃើញបាន, ពន្លឺទាំងនោះ ដែលមកស្ថិតនៅក្នុងពួកឫសីបាន មិនមែនមកពីគានសាស្ត្រ(១) ឬដោយអត់អាហារទាល់តែរូបនោះទ្រោមអនិច្ចកម្មនោះទេ; តែពន្លឺនោះមាន; ទូលបង្គំបំណងនឹងទៅរកពន្លឺនោះឲ្យឃើញ, ស្វែងរកធម៌ពិតឲ្យយល់,

---

១ សាស្ត្រៈ គម្ពីរពិសិដ្ឋជាតិឥណ្ឌាមានសៀវភៅ៤ភាគ សាលសា. ទស្សនវិជ្ជាគណិតសាស្ត្រ, វេយ្យាករណ៍, ធម្មសាស្ត្រ និងគម្ពីរវេទវណ្ណា ។

ដល់ទូលបង្គំឃើញធម៌នោះវេលាណា ទូលបង្គំនឹងវិលត្រឡប់មកបំពេញករណីយកិច្ចចំពោះព្រះមហាក្សត្រិយ៍ក្នុងវេលានោះមិនខាន” ។

ព្រះបាទពិម្ពិសារ ទ្រង់បានធ្វើប្រទក្សិណព្រះអង្គម្ចាស់បីជុំ, ឱនព្រះសិរសាគោរពជិតព្រះបាទាព្រះពោធិសត្វ ហើយថ្វាយពរសព្ទសាធុការថា “សូមឲ្យបានសម្រេចដូចព្រះរាជបំណង” ។ រួចព្រះពោធិសត្វព្រះអង្គនិមន្តទៅកាន់ឧរុវេលៈ (ឧរុវេលសេនានិគម) តែព្រះទ័យរបស់ព្រះអង្គមិនទាន់រកធម៌នោះឃើញនៅឡើយ; ព្រះភ័ក្ត្រព្រះអង្គស្វាយស្លេកស្លាំង ហើយព្រះកាយពលអន់ខ្សោយដោយការស្វះស្វែងរកធម៌នេះ (បំពេញទុក្ករកិរិយា) អស់រយៈ ៦ ឆ្នាំ រួចពីនោះព្រះអង្គបាននិមន្តទៅសំណាក់ក្នុងពួកបណ្ឌិត (ព្រាហ្មណ៍) នៅជិតក្នុងនឹងអជនប្រទេស គឺអាឡារតាបសនិងឧទកតាបស ព្រមទាំងឥសី ៥ នាក់ដែលបានសំដែងពិតទូលព្រះអង្គអំពីធម៌ពិត ដែលបានពណ៌នានូវគម្ពីរសាស្ត្រ គឺគ្មានអ្នកណាបំណងឲ្យបានដល់ឋានខ្ពស់ជាងពួកស្រោតិ (Srouti) និងស្ម្ឫតិ (Smriti)[១] បើទុកជាលោកណា ដែលជាសទ្ធិបុគ្គលវិសេសក៏ដោយ ។ ព្រោះថា ធម្មតាមនុស្សបុថុជ្ជនមិនដែលមានអ្នកណាចេះជាងគម្ពីរញាណ-

---

១ ស្រោតិ (សំស្ក្រឹត)= ធម៌ពីតដែលរកឃើញ, ដែលមានទៅគម្ពីរវេទ ។ ស្ម្ឫតិ= សៀវភៅធម៌ទាំងអស់ ដែលពួកឥសីពីបុរាណរៀបរៀង ។

កណ្ឌ (Jnana-Kand) (១) ដែលថ្លែងថា ព្រះព្រហ្មជានាមធម៌, មិនប្រតិបត្តិការអ្វីទេនៅស្ងៀមស្ងាត់. ព្រះទ័យស្ងប់ដែលគេមិនអាចប្រៀបធៀបទៅនឹងអ្វីបានឡើយ, មិនចេះប្រែប្រួល, មានជីវភាពបរិសុទ្ធផុតមន្ទិលសៅហ្មង, មនោគតិស្អាត, គួរជាទីគោរពពន់ពេក, ឬមនុស្សសាមញ្ញមិនមានអ្នកណាអាចចេះជាន់គម្ពីរ កម្មិកណ្ឌ (Karma-Kand) (២ ដែលបង្ហាញនូវពិធីលះបង់នូវបាបអកុសលនឹងកម្មិកភាព បំបាត់នូវប្រពក់នៃអាត្មន ហើយចេញក្រៅពីវ័ដ្ត ប្រែទៅជាព្រះ (Dieu) រលាយទៅជាមួយនឹងសុខុមធម៌, ពោះពាំពីសភាពខុសទៅរកសភាពត្រូវ, ការតស៊ូនឹងកាមារម្មណ៍ ដើម្បីនឹងបានទៅដល់ស្ថានបរមសុខ ដែលមានតែសភាពស្ងាត់ស្ងៀមទេ ។

តែព្រះពោធិសត្វទ្រង់ជ្រាបសេវនាពួកឥសីទាំងនោះ ហើយព្រះអង្គនៅតែមិនទាន់ពេញព្រះទ័យ ។

(មានត)

---

១ ញាណៈកណ្ឌ (សំស្ក្រឹត : សៀវភៅខាងវិទ្យាសាស្ត្រ, ជាផ្នែកនៃផ្នែកលម្អិតគម្ពីរពេទ ) ។

២ កម្មិកណ្ឌ (សំស្ក្រឹត សៀវភៅខាងជាតិចរិតធម៌, ផ្នែកខាងគម្ពីរព្រាហ្មណ៍គម្ពីរវេទ ។

កាំឡាំងនៃពាក្យញុះញង់

# ឃុន បណ្ណកុរ័ក្ស ប៊ូ.ប៉ូ ទៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(ត-ចប់)

---

ព្រះមហាក្សត្រត្រាស់យ៉ាងនេះហើយ ទ្រង់ត្រាស់គាថាតទៅទៀតថា

រតជាកាភេរ គម្ភីរេ   មាលុតេន ច ខុភិតោ
តារជភេ ភូមិចាលោ   អមច្ចេនេវ ខុភិតោ
ន ហោតិ បត្តោ កាភេ   ន កាភោ សត្តសាគរេ
មិត្តទុត្ថិ ជភេ ភាភេ   វិសាសឧត្តកោ ជនោ
បឋវី សាគរេ មេរុ   ខយំ យន្តិ យុគក្ខយេ
កប្បានំ សតសហស្សានំ   ទុត្ថិចាបំ ន បស្សតិ
កណ្ណជប្បម្បិ កាត្វាន   កុលេ ភបិ វិជាសកា
ចាសាណាប្បល្ហកុដារ   ឧទកោនេវ ភេទកា ។

“អណ្ណងកែវគងទ៏ជ្រៅ ៗ នៅតែខ្យល់បក់ឲ្យរង្គើកំរើកបាន ព្រោះរាជាម្ចាស់ផែនដីគ្រប់គ្រងនគរ ពួកអាមាត្យអាចធ្វើឲ្យកម្រើកញាប់ញ័របាន ; ភ្នំទីងសមុទ្រទាំងពួងមិនទុកជាជារបស់ធ្ងន់ទេ នរជនអ្នកទ្រស្តម្ភ អ្នកធ្វើឲ្យបែកបាក់សេចក្ដីស្និទ្ធស្នាលរបស់គេទើបធ្ងន់ ; ផែនដីទីងសមុទ្រភ្នំ ដល់វេលាអស់យុគនៃសែនកប្បហើយ ក៏រមែងវិនាសសាបសូន្យ

ទៅទាំងអស់, មនុស្សដែលគិតតែញុះញង់បំបែកបំបាក់មិត្តសំឡាញ់គេ មិនឃើញនូវបាបកម្ម ដេះតែធ្វើការខ្សឹបក្បែរត្រចៀកគឺការញុះញង់គេ មាននៅក្នុងត្រកូលណា ក៏អាចធ្វើត្រកូលនោះឲ្យវិនាសខ្ចាត់ខ្ចាយទៅ ប្រៀបដូចជាដុំថ្មដ៏ធំប៉ុនជាលដាក់ស្រូវត្រូវទឹកហូរយ៉ាងខ្លាំងបោកបំបែកល្អិត ខ្ទេចខ្ទីទៅបាន" ។

តាំងពីពេលនោះមក ព្រះមហាក្សត្រត្រាស់បង្គាប់ឲ្យគេចាប់មនុស្សដែលញុះញង់គេ បានហើយឲ្យបណ្ដេញចេញអំពីដែន ព្រមទាំងឲ្យលើកទោសទោលខ្លះតាមគួរ, កាលព្រះអង្គទូន្មានប្រជារាស្ត្រទ្រង់ត្រាស់គាថាថា៖

ជីវិតម្បិ ចជិត្វាន    កេនចិ ន ការយេ
កាយវចញ្ច រក្ខិត្វា    វិចារេត្វា ការយេ
និសម្ម បណ្ឌិតា ការយំ    ជាតិសម្មាប់ ការយំ
វិមំសិត្វា វិចារេត្វា    បញ្ញា ន អនុតប្បតិ
យថា សុវណ្ណរាជិសាបិ    គោនចំ បរិកេនិតា
ភិន្ទន្តស្ស គហេត្វាន    អញ្ញមញ្ញំ ភេទិតា
ឯកោ អញ្ញោ និវេសេតិ    ឯកោ ពហិ និវេសតិ
អញ្ញមញ្ញំ អសំសដ្ឋា    មុចេជាបិ អនុសិតា ។

"បើទុកជាជីវិតនឹងក្ស័យ បុគ្គលក៏គប្បីធ្វើទោស គឺការចាក់រុកគ្នាឲ្យបែកបាក់ឡើយ គប្បីសម្រួលកាយវាចាពិចារណាឲ្យ

ល្អិតល្អហើយទើបធ្វើតែអំពើដែលត្រូវ, អ្នកប្រាជ្ញទាំងឡាយលុះតែត្រិះរិះពិចារណារួចហើយទើបបានធ្វើ, បើលោកមិនទាន់បានពិចារណាជាមុនលោកមិនធ្វើទេ; បុគ្គលមិនត្រិះរិះពិចារណាជាមុនហើយចេះតែធ្វើៗ ទៅរមែងបានសេចក្ដីក្ដៅក្រហាយខាងក្រោយ ដូចជាហង្សមាសក្បាលពីរខ្លួនមួយជាប់គ្នា ត្រូវអាមាត្យអ្នកញុះញង់ឲ្យបែកគ្នា បែកាន់សំដីរបស់អាមាត្យអ្នកញុះញង់ក៏បែកខ្លួនចេញពីគ្នាជាពីរ, ហង្សមួយទុកបញ្ចាំមកក្នុងព្រះរាជវាំង, ហង្សមួយទុកឲ្យនៅក្រៅវាំង បែកខ្វែកព្រាត់ប្រាសគ្នាលើញជាក់ស្ដែងនឹងភ្នែក" ។

លំដាប់ពីនោះមក ព្រះមហាក្សត្របានសោយរាជសម្បត្តិដោយធម៌ដ៏ស្មើ ប្រជារាស្ត្រមានចិត្តស្មោះស្ម័គ្រស្លូតត្រង់នឹងគ្នា ប្រព្រឹត្តកាយវាចាចិត្តជាសុចរិតរៀបរយល្អ ។ ព្រះបាទពារាណសីទ្រង់បំពេញបារមីទាំង ៣០ ប្រការ លុះដល់វេលាទិវង្គតហើយបានទៅកើតក្នុងទេវលោក, ក្នុងជាតិជាទីបំផុតបានសោយព្រះជាតិជាព្រះបាទវេស្សន្តរ ទ្រង់បំពេញសត្តសតកមហាទាន ដល់ទិវង្គតទៅកើតក្នុងតុសិតបុរី, លុះព្រះបារមីពេញបរិបូណ៌ហើយ ទេវតាក្នុងម៉ឺនចក្រវាឡទូលអារាធនាឲ្យច្យុត, ព្រះអង្គបានពិចារណាមើលមហាវិលោកនៈទាំង ៥ ស្រេចហើយ - ក៏ច្យុតចាកតុសិតសួគ៌មកចាប់បដិសន្ធិក្នុងព្រះឧទរនៃព្រះនាងមហាមាយា, រាប់ចាប់ដើមពីប្រសូតមករហូតដល់ព្រះជន្មបាន ២៩ ឆ្នាំ មានព្រះរាជទ្រព្យ ១ អង្គ

ព្រះនាមរាហុលកុមារ, ក្នុងវេលាត្រីកណ្តាលអធ្រាត្រថ្ងៃមួយព្រះអង្គប្រាថ្នានឹងទ្រង់ព្រះផ្នួស មានទេវតាក្នុងមុំទបក្រោកឡើងនឹងនាយឆន្នអាមាត្យតាមហែទៅផង ស្តេចចេញកាន់មហាភិនិក្ខ្រមន៍ ទ្រង់បំពេញមហា-បធានវីរិយៈនៅក្នុងព្រៃដល់ ៦ ឆ្នាំ ព្រះអង្គបានសោយមធុបាយាសដែលនាងសុជាតានាំមកថ្វាយ ហើយស្តេចឡើងគង់លើពោធិបល្ល័ង្ក បែរព្រះភក្ត្រទៅទិសបូព៌ាតាំងព្រះទ័យដោយសមាធិចិត្ត ទ្រង់ផ្ចាញ់ស្តេចមារព្រមទាំងពល ហើយក៏បានត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ, តាំងពីនោះមកព្រះអង្គទ្រង់ប្រទានព្រះធម៌ទេសនាដល់ទេវតា និងមនុស្សជាលំដាប់មក. ព្រះអង្គនឹករឭកដល់ពាក្យស្លឹកជាតក ទើបលើករឿងនោះមកអាងជាមូលហេតុហើយសំដែងព្រះធម៌ទេសនា ដោយន័យគាថាប៉ុណ្ណោះជាដើមថា ។

មិត្តបិយេសុ ភជេថ អមិត្តញ្ច ន សេវយេ

សុក្កធម្មំ បវត្តេថ កណ្ហធម្មំ ន សេវិត្ត ។

"អ្នកទាំងឡាយចូរសេពគប់តែមិត្តដែលជាទីស្រឡាញ់ ចូរកុំសេពគប់នឹងមនុស្សជាអមិត្ត ចូរប្រព្រឹត្តធម៌ស កុំសេពធម៌ខ្មៅ, មួយទៀតមនុស្សល្អកាលបើទៅសេពគប់នឹងមនុស្សអាក្រក់ហើយ ក៏ទៅជាអាក្រក់ដូចគ្នា, បុគ្គលសាបព្រោះបណ្ដុះពូជយ៉ាងណា រមែងបានផលយ៉ាងនោះ, អ្នកធ្វើអំពើល្អរមែងបានផលល្អ អ្នកធ្វើអំពើអាក្រក់

រមែងបានផលអាក្រក់, អ្នកទាំងឡាយកុំសេពគប់នឹងបុរសបោកឆោត គប្បីសេពគប់នឹងបុរសដែលល្អៗតែម្យ៉ាង, បុគ្គលយកមនុស្សបែបណា មកធ្វើជាមិត្ត ស្និទ្ធស្នាលនឹងមនុស្សបែបណា អ្នកសេពគប់ស្និទ្ធស្នាល នោះរមែងក្លាយទៅតាមគ្នាបាន, ចំណែកលោកអ្នកមានបញ្ញាមិនហ៊ាន សេពគប់នឹងមនុស្សអាក្រក់ទេ ព្រោះខ្លាចសេចក្តីអាក្រក់នោះប្រឡាក់ ដល់ខ្លួនលោក, អ្នកណាខ្ចប់ត្រីស្អុយដោយស្លឹកស្បូវក្លាំងៗ នោះក៏ស្អុយទៅ តាមផងដូចម្តេច ការសេពគប់នឹងមនុស្សពាលក៏មានអាការដូច្នោះដែរ ។ អ្នកណាខ្ចប់ក្រស្នាដោយស្លឹកឈើៗនោះ ក៏មានក្លិនក្រអូបទៅតាមផង ដូចម្តេច ការសេពគប់នឹងបណ្ឌិតរមែងក្រអូបដូច្នោះដែរ, មនុស្ស អសប្បុរសរមែងទៅនរក មនុស្សសប្បុរសមានស្ថានសួគ៌ជាទីទៅខាង មុខ, អ្នកស្វែងរកទោសដាក់គេរមែងទំលាយបំផ្លាញមនុស្សពួកប្រែឲ្យ វិនាស នាយព្រានព្រៃល្បួងបញ្ឆោតសត្វម្រឹគដោយឧបាយកល ឲ្យមក កាន់សំណាក់ខ្លួន ហើយសម្លាប់យកតាមចិត្តបានយ៉ាងណា មនុស្ស ទាំងឡាយល្បួងបញ្ឆោតមហាជនដោយបាយទឹកនឹងវាចាផ្អែមល្ហែម ស្វែង រកទោសគេបានតែបន្តិចបន្តួចហើយ ក៏ធ្វើទុកទោសឲ្យកើតឡើងបំផ្លាញ សេចក្តីល្អរបស់គេឲ្យសាបសូន្យអស់ទៅដូច្នោះដែរ ។

មួយទៀត ខ្ចប់ចកនឹងសត្វស្វា ទាំងឡាយដែលចិត្តគាប់ល្អហើយ នៅជាមួយគ្នាបាន, ឯមនុស្សនៅជាមួយនឹងមនុស្សដូចគ្នាលំបាកណាស់

កម្រើនដីនប៉ិត្តគាបាន, ដ្បិតចិត្តរបស់មនុស្សតែងតែប្រែប្រួលទៅក្នុងខណៈៗ; ព្រោះហេតុនោះ បុគ្គលគប្បីវៀរចាកទោសគឺការញុះញង់គេឲ្យឃ្លាតចេញឆ្ងាយពល់រំលោះ, ទោសនៃការបែកបាក់បាក់គ្នាកើតមានឡើងព្រោះតែពាក្យញុះញង់. អ្នកពេញចិត្តតែងខាងការញុះញង់គេព្រមទាំងធ្វើឲ្យបែកខ្ញែកគ្នា រមែងទៅនេះកងនរកអស់សែនកប្ប កាលផុតពីនរកមកហើយ ទីងកើតជាមនុស្ស ក៏ជាមនុស្សរាល់ក្រពិតលពិការកាយាទាំងជាមនុស្សកំព្រាអនាថា មានកាយាដូចប្រេតខ្មួរខ្មើម អត់បាយក្រហាយទឹក ទាំងនេះក៏ព្រោះទោសនៃការធ្វើឲ្យគេបែកបាក់គ្នាឲ្យផលមក, អ្នកញុះញង់គេខុះទៅកើតជាប្រេតស៊ីតែជន្លរជាអាហារ, អ្នកប្រាជ្ញដែលមានប្រាជ្ញាណលោកឃើញទោសយ៉ាងនេះហើយ បានជាលោកវៀរចាកការញុះញង់ឲ្យឃ្លាតឆ្ងាយពីសន្តានចិត្ត; ការធ្វើអាក្រក់ទីងធ្វើល្អទុកមក រមែងបានផលអាក្រក់ទីងផលល្អដូច្នោះឯង មិនត្រូវសង្ស័យឡើយ ៗ

សម្តេចព្រះបរមសាស្តា កាលទ្រង់ប្រកាសអានិសង្សនៃសេចក្តីសាមគ្គី ទ្រង់ត្រាស់គាថានេះជាដើមថា :

យេ សមគ្គា បុញ្ញវគា ឯកចិត្តសមាហិតា

បប្បោន្តិ សត្តសម្បត្តិំ វិសេសំ ចាតុណាសុ ជិតុអិ ៗ

អ្នកណាត្រេកអរនឹងបុណ្យ មានមេត្រីចិត្ត ជាទីកចិត្តមួលមួយគ្នា

អ្នកនោះរមែងដល់នូវសម្បត្តិសួគ៌និងគុណវិសេសយ៉ាងធំក្រៃលែង ខាងក្រោយនឹងដល់ព្រះនិព្វានជាទីក្សេមក្សាន្តប្រាសចាកភ័យ ។

មួយទៀត អ្នកនោះកាលនឹងរង្គាត់ទៅក្នុងសង្សារវដ្ត ជាអ្នកមានញាតិសន្តានច្រើនព្រមព្រៀងមូលបិត្តគ្នា ដូចរុក្ខជាតិដែលកើតច្រើននៅក្នុងព្រៃដូច្នោះដែរ, សេចក្តីព្រមព្រៀងគ្នាជាគុណអាចនឹងការពារនូវអន្តរាយដែលនឹងមានមកដល់ខ្លួនឲ្យផុតទៅបាន ប្រៀបដូចសត្វជ្រូកមានហ្វូងធំច្រើនស្រុះបិត្តគ្នា រមែងអាចនឹងចាប់ខ្លាធំមួយដ៏កាចសាហាវទាំងសម្លាប់បាន ។ ព្រោះដូច្នោះ លោកទាំងឡាយ ចូរត្រេកអរក្នុងអប្បមាទធម៌ ចូររក្សាចិត្តទុកឲ្យល្អ គប្បីរក្សាកាយវចីមនោទ្វារទុកឲ្យល្អរាល់ថ្ងៃ គប្បីលះបង់សំដីញុះញង់ចេញ នឹងចៀសវាងការឈ្លោះប្រកែកគ្នាចេញឲ្យឆ្ងាយពីសន្តានគ្រប់ថ្ងៃ, អ្នកប្រកបដោយសាមគ្គី នឹងមានតែសេចក្តីសុខគ្រប់ឥរិយាបថ ហើយនឹងបានអានិសង្ស ១១ ប្រការ (តែព្រះសាស្តាមិនបានសំដែងទុកក្នុងទីនេះទេ) ។

សត្ថា ឥមំ ធម្ម ទេសនំ អាហរិត្វា សម្តេចព្រះបរមសាស្តាទ្រង់នាំព្រះធម៌ទេសនានេះចប់ហើយ ទើបប្រជុំជាតកថា "នាយព្រានព្រៃក្នុងគ្រានោះត្រឡប់ជាតិមកគឺព្រះឆន្នត្ថេរ, ហង្សមាសមួយក្នុងគ្រានោះត្រឡប់ជាតិមកគឺព្រះគិរិមានន្ទត្ថេរ, ហង្សមាសមួយទៀតក្នុងគ្រានោះ

ត្រឡប់ជាតិមកគឺព្រះកាឡុទាយិត្ថេរ, អាមាត្យអ្នកឈ្លាសវៃក្នុងគ្រានោះ ត្រឡប់ជាតិមកគឺព្រះសារីបុត្តត្ថេរ, បរិស័ទទាំងឡាយក្នុងគ្រានោះត្រឡប់ ជាតិមកគឺពុទ្ធបរិស័ទ, ព្រះបាទពាកណសីក្នុងគ្រានោះត្រឡប់ជាតិមក គឺតថាគត" ។ មានពុទ្ធវចនៈឲ្យចប់ចុះដោយប្រការដូច្នេះ ។

ពាកណសីរាជជាតក ចប់ ។

សុភាសិត

បុរាណជាសុភាសិតរបស់ខ្លួនដោយខ្លួនឯង ។

សេចក្ដីបរិសុទ្ធិនឹងមិនបរិសុទ្ធិ ជារបស់ចំពោះខ្លួន

អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបាន ។

---

ប្រទេសឯករាជ្យ មានសេចក្ដីលំបាកវេទនាដំបូង

តែខាងក្រោយមក មានសេចក្ដីក្សេមក្សាន្តថ្កើងថ្កាន ។

ប្រទេសខ្ញុំគេ មានសេចក្ដីធូរស្រួលដំបូង

តែខាងក្រោយមក មានសេចក្ដីវេទនាជាអនេក ។

# ពិធីសម្ពោធបើកសាលាធម្មវិន័យ

### នៅវត្តព្រះព្រហ្មរតន៍ សៀមរាប

## ព្រះមហា កែ-អឿន រៀបរៀង

កាលពីថ្ងៃពុធ ១២ កើតខែទុតិយាសាឍ ឆ្នាំខាលទោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥០, នៅវត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប មានធ្វើពិធីដ៏ឧឡារិក ហៅថា: "បុណ្យសម្ពោធបើកសាលារៀនធម្មវិន័យ" ។ ក្នុងពិធីបុណ្យនេះ ល្អចំឡែកអស្ចារ្យពន់ពេក គឺសាលាធម្មសភាតាំងមូលនឹងសាលាធម្មវិន័យ មានរៀបគ្រឿងសក្ការបូជាថ្វាយដល់ព្រះរតនត្រ័យ, គ្រឿងសក្ការនោះប្រដាប់ដោយស្លឹកផ្កា-ឈើស្រស់បំរុះពណ៌ទីទៃៗ នឹងទង់ជាតិតូចធំជាច្រើន ។ ត្រង់ផ្ទៃកណ្ដាលសាលាធម្មសភា មានក្ដារខៀនបញ្ឈរធំមួយតែងជាត្រៃសរណដ្ឋាន គឺ ជាតិ-សាសនា-មហាក្សត្រ ។ នៅកណ្ដាលក្ដារខៀននោះមានសរសេរអក្សរធំៗ ទង់ជាតិពីរបង់ខ្សែរ៉ែត្របិទមិនឲ្យឃើញអក្សរ ទុកបំរុងឲ្យលោកជាឥស្សរជនទាញបើក ។ ខាងលើក្ដារខៀននោះគេតម្កល់ព្រះពុទ្ធរូបកញ្ចក់មួយព្រះអង្គ, ចុងក្ដារខៀនទាំងសងខាង គេតម្កល់ព្រះបរមរូបព្រះករុណាជាម្ចាស់ជីវិត នឹងរូបអ្នកអង្គម្ចាស់យុគន្ធរ, ខាងមុខក្ដារខៀន មានតុ ១ តម្កល់ព្រះត្រៃបិដក ។ បន្ទាប់ពីនោះគេរៀបកៅអីជាពីរ

ផ្ទះទឹកតុះតម្កល់ផ្កាសម្រាប់វក្ខាត់ស្បូវផង, ប៉ុន្តែការរៀនសនទាងមុខព្រះរូបទាំងពីរ គេដាក់ដំដែកការពារតម្កល់តម្កើរសាស្ត្រា ៗ តាំងពីមុខសាលាទៅគេរៀបធ្វើជាកដរតិប្រដាប់ដោយស្លឹកឈើស្រស់ខ្វាត់ខ្វែង ទីងទង់ជាតិជកបដល់ក្លោងទ្វារធំកំពែងក្រៅ ។ វេលាម៉ោងពីរ ២០ នាទីរសៀលព្រះសង្ឃជាង ១០០ អង្គ មានព្រះតេជព្រះគុណព្រះសុមង្គល-សីលាចារ្យមេគណ និងព្រះតេជព្រះគុណព្រះគ្រូបញ្ញាវិជ្ជាអនុគណជាប្រធាន និងពុទ្ធបរិស័ទជាច្រើន គុះករជាងពាន់នាក់បាននិមន្តនិងអញ្ជើញទៅជួបជុំនៅសាលាធម្មសភា ត្រៀមចាំបដិសណ្ឋារៈទទួលលោកឧកញ៉ាព្រះពជប្រតិភូ (ទេព - ជន) និងលោកវរសេនីយត្រី (ឈួនមូលពេជ្រ) ព្រមទាំងឥស្សរជនខ្លះក្នុងខេត្ត ។ នៅពេលនេះមានគេចង់រូបម្គង ៗ វេលាម៉ោងបី ២០ នាទី អស់លោកជាឥស្សរជនអញ្ជើញទៅដល់, ក្រុមភ្លេងលេងភ្លេងនគររាជទទួល ៗ លុះឥស្សរជនអញ្ជើញទៅដល់ថ្វាយបង្គំចំពោះព្រះសង្ឃរួចហើយក៏អង្គុយលើកៅអី ដោយឯកប្បហារ ។ ក្រោយពីនោះបន្តិចមកមានឧបាសកម្នាក់យកខ្សែដែលចងទង់ជាតិទាំងសងខាងជូនទៅលោកឧកញ៉ាព្រះពជប្រតិភូ ឲ្យទាញបើកក្តារបញ្ជរនោះ លោកក៏ទាញបើកភ្លាម ទង់ជាតិទាំងគូក៏របើកចេញពីគ្នាស្រុះទៅនៅចុងក្តារទាំងពីរខាង ។ ពេលនោះគេមើលឃើញអក្សរសរសេរនៅក្តារថា:

សាលារៀនជហ្មវ័យ

វត្តព្រះព្រហ្មរតន៍

ធម្មនិយោ សាសនស្ស មូលំ

ធម្មវិន័យជាឫសកែវនៃសាសនា, សាសនាជាពន្លឺនៃប្រទេសជាតិ

កម្ពុជោ ភូមិសេដ្ឋ ភវេ

សូមឲ្យប្រទេសកម្ពុជា រួចចាកទាសភាព

ពេលនោះ ភ្លេងពិណពាទ្យក៏ពេទ៌គឹកកងរំពងឡើងទទួលអំណរ, លុះបប់ភ្លេងហើយ ព្រះមហាកែ-អឿន សូត្រសុន្ទរកថា ដោយទ្រគ្យាសនុសព្ទ ដូចមានសេចក្តីទៅនេះ :

## សុន្ទរកថា

ខ្ញុំព្រះករុណា អាត្មាភាព ជាតំណាងព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណទីពជាគណ : នឹងព្រះតេជព្រះគុណព្រះគ្រូបញ្ញាទីជាអនុគណ នឹងភិក្ខុសង្ឃទាំងអស់ ព្រមទាំងពុទ្ធបរិស័ទ្យជាបំណុះដើងវត្តនេះ ។

សូមពិតថេរវាចា ព្រះករុណាគប់ព្រះអង្គ !

សូមចំរើនពរព្រះតេជព្រះគុណលោកអ្នកឧកញ៉ា ព្រះរាជប្រតិភូ !

ព្រះតេជព្រះគុណលោកវរសេនីយត្រី នាយកកងឯកទេសខ្មែរ!

និង លោកសប្បុរសជនទាំងឡាយក្នុងខែត្រទាំងអស់ !

សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព មានសេចក្តីត្រេកអរដ៏ពន្លឹក និងមានអំណរគុណដ៏ក្រៃលែង ចំពោះព្រះករុណាគ្រប់ព្រះអង្គនិងអស់លោក-អ្នកទាំងឡាយ ដែលបាននិមន្ត អញ្ជើញមកជាមង្គល និងជាកិត្តិយស ក្នុងឱកាសបុណ្យសម្ពោធបើកសាលារៀនធម្មវិន័យថ្មីនេះ :

ព្រះករុណាគ្រប់អង្គ !

ព្រះតេជព្រះគុណលោក៖កញ្ញាព្រះរាជប្រតិភូ !

ព្រះតេជព្រះគុណលោកវរសេនីយត្រី !

អស់លោកសប្បុរសជនទាំងឡាយ !

ពេលនេះខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងការណ៍នៃកិច្ចរៀនសូត្រធម៌វិន័យក្នុងព្រះពុទ្ធសាសនាដោយសេចក្តីសង្ខេប ដូចតទៅនេះ ៖

ធម្មវិន័យជាបុសកែវនៃព្រះពុទ្ធសាសនា ជាសភាវៈសំដែងបំភ្លឺនូវផ្លូវលោកនិងផ្លូវធម៌ ។ ក្នុងលោកទាំងមូល លុះតែមានទាំងផ្លូវលោកផ្លូវធម៌ស្មើគ្នាគ្រប់កាល ទើបបានសេចក្តីសុខ សេចក្តីចំរើនថ្កើនរុងរឿងជានិច្ច, បើមានតែផ្លូវលោកមួយចំណែកមិនមានផ្លូវធម៌សោះ លោកនឹងក្តៅឆេះជាភ្លើង, បើមានតែផ្លូវធម៌មួយចំណែកមិនមានផ្លូវលោកសោះ លោកនឹង

ក្លាយទៅជាព្រៃ, ហេតុនោះផ្លូវលោកនិងផ្លូវធម៌ត្រូវអាស្រ័យគ្នាទៅវិញទៅមកគ្រប់កាលទើបប្រព្រឹត្តទៅបាន, ប្រៀបដូចជាគោ ១ ទឹមនឹងអូសនូវភារៈដ៏ធ្ងន់ លុះតែគោទាំងគូព្រមអូសទៅស្មើគ្នាទើបប្រព្រឹត្តទៅរួច សេចក្ដីនេះយ៉ាងណា ឯផ្លូវលោកនិងផ្លូវធម៌ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ព្រះតេជព្រះគុណព្រះរាជប្រតិភូ និងព្រះតេជព្រះគុណវរសេនីយត្រីនាយកកងឯកទេសខ្មែរ កាលបានជ្រាបការណ៍នេះដោយជាក់ច្បាស់ ទើបលោករួបរួមជាមួយនឹងអាត្មាភាពជាមេគណនិងអនុគណជួយឧបត្ថម្ភផ្ដើមបង្កបង្កើត ឲ្យមានសាលាសិក្សាធម្មវិន័យនេះរៀងសម្រាប់បណ្ដុះធម្មវិជ្ជា នៃសិក្ខាកាមកុលបុត្រដែលបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ជាគុណនាំព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿង និងជាប្រទីបពន្លឺនៃប្រទេសជាតិ ។

អាត្មាភាពមានសេចក្ដីនឹកសង្ឃឹមតក់ក្ដៅក្នុងចិត្តថា: ក្នុងខែត្រសៀមរាបនេះ មិនយូរប៉ុន្មានទៀតនឹងទៅជាខែត្រ ១ សម្បូណ៌ដោយធម្មវិន័យនិងវប្បធម៌ខាងព្រះពុទ្ធសាសនា ជាទិដ្ឋានុគតិនៃខែត្រនានាក្នុងកម្ពុជរដ្ឋឲ្យសមរំទៅតាមឋានៈជាប្រទេសឯករាជ្យ ដោយសារសេចក្ដីឧបត្ថម្ភរបស់ព្រះតេជព្រះគុណព្រះរាជប្រតិភូ និងព្រះតេជព្រះគុណវរសេនីយត្រីនាយកកងឯកទេសខ្មែរ ព្រមទាំងលោកជាសប្បុរសជនក្នុងខែត្រមិនខាន ។

ក្នុងកាលជាអវសាននៃសុន្ទរកថានេះ អាត្មាភាព សូមបួងសួងដល់

គុណព្រះរតនត្រ័យ និងទេវតាទាំង ១ ហ្នឹងលោកធាតុ សូមជួយបីបាច់រក្សាព្រះតេជព្រះគុណសាស្ត្រាចារ្យទាំងឡាយ ឲ្យបានប្រកបដោយសេចក្តីសុខ សេចក្តីចំរើន និងបានបរហេសក្តិជាលំដាប់និងមានជន្មាយុយឺនយូរអង្វែង ដើម្បីនឹងជួយបំរើមាតុភូមិឲ្យអណ្តែតត្រសែតទៅកាន់វឌ្ឍនធម៌ និងឯកភាពដោយសម្បូណ៌ និងបំពេញកិត្តិយសចំពោះទង់ជាតិមានប្រាសាទនគរវត្តជាជំនិមិត្តរូប ។ ម្យ៉ាងទៀតសូមជូនសព្ទសាធុការពរដល់ពុទ្ធបរិស័ទទាំងឡាយព្រមទាំងញាតិគ្រួសារ ឲ្យបានសេចក្តីសុខសេចក្តីចំរើនក្នុងព្រះពុទ្ធសាសនា ដរាបដល់ព្រះនិព្វានជាអវសានជាតិកុំបីឃ្លាត ។

បន្ទាប់ពីសុន្ទរកថានេះ លោកឧកញ៉ាព្រះរាជប្រតិភូថ្លែងបាឋកថាពិតថេរកថាដល់ព្រះសង្ឃឲ្យខំតំរៀនសូត្រធម៌វិន័យ ដោយលោកមានសេចក្តីពេញចិត្តជាទីបំផុត ។

តមកទៀត លោកវរសេនីយ៍ត្រីនាយកឯកទេសខេត្រថ្លែងការណ៍ទទួលអំណរដែលបានបង្កើតសាលាធម្មវិន័យនេះ ហើយពន្យល់ព្រះសង្ឃឲ្យមករៀនធម្មវិន័យ ព្រមទាំងប្រដៅប្រជាជនឲ្យមានសាមគ្គីធម៌ដើម្បីជួយមាតុភូមិឲ្យបានឯករាជ្យពេញលេញជាដើម ។

– ក្រោយពីនោះ លោកពលបាលឯក ចក់-ពេជ្រ ប្រកាសឃោសនាដល់ពុទ្ធបរិស័ទ ឲ្យជួយឧបត្ថម្ភដោយចតុប្បច្ច័យដល់ព្រះសង្ឃ

ដែលរៀនសូត្រ ។ ពេលនោះលោកវរសេនីយត្រី មានសទ្ធាជ្រះថ្លា ចូលជួយឧបត្ថម្ភការសិក្សា ១.០០០ រៀល, ចំណែកពុទ្ធបរិសទ្យជា ច្រើនក៏បានជាវសៀវភៅ ស្វាយប៉ាកកា - ទៅដៃជាដើម មានចំនួនច្រើន ឧបត្ថម្ភការសិក្សា ។

— រួចកិច្ចឃោសនាហើយ លោកឧកញ៉ាព្រះរាជប្រតិគ្រូប្រគេន ប្រកាសសនីយបត្រ ២ សន្លឹក ដល់ព្រះមហាកែ - អឿន និងព្រះមហា សុខ - សាន តាំងជាសាស្ត្រាចារ្យ ឲ្យបង្រៀនធម្មវិន័យ ។

— ខាងចុងបំផុត លោកគ្រូព្រះវិនយធរឯក - ញឹម ថ្លែងបាឋកថា អំពីអានិសង្សនៃការរៀនសូត្រនិងបំណេះវិជ្ជា យ៉ាងពីរោះក្បោះក្បាយ ។

លុះចប់ករណីយកិច្ចទាំងនេះហើយ ព្រះសង្ឃសូត្រជយន្តោគឹកកង រំពងឡើង គួរឲ្យមានសេចក្តីជ្រះថ្លាក្រៃពេក ។ កិច្ចបុណ្យឈ្មោះថាចប់ ពិធីបុណ្យសម្ភោធឲ្យបើកសាលាធម្មវិន័យ ។ លុះចប់កិច្ចនេះហើយ លោក ជាតស្សរជនក៏ថ្វាយបង្គំលាព្រះសង្ឃ និងសំពះលាពុទ្ធបរិស័ទ្យចេញទៅ ដោយគារវភាព ។ ពេលនោះព្រះសង្ឃមានព្រះមេគណនិងអនុគណ ជាដើមបានជូនដំណើរ ក្មេងគូរូតន្ត្រីក៏ប្រគំភ្លេងហ៊ឹងអឹងកងរំពងឡើងជា កិត្តិយស ជូនដំណើរលោកជាតស្សរជនអញ្ជើញទៅវិញ, ពេលនេះ មានប្រជុំជនជាច្រើនលើក លុះគេជួបជុំហើយ លោកជាតស្សរជន អញ្ជើញឡើងរថយន្ត ទៅកាន់គេហស្ថានដោយសុវត្ថិភាពរៀងៗខ្លួន ។

ចប់

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

# របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៩២ ចុះថ្ងៃចន្ទ ១ កើតខែអាសាឍឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ ខៀវ-ជា នាមឆាយា ធម្មជោត កើតឆ្នាំច អាយុ ៤០ វស្សា ៧ ជាចៅអធិការវត្តពោធិវ័ន ឃុំស្មោ- ស្រុកកំពេញ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ៦៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-សាយ នាមឆាយា ព្រហ្មសុវណ្ណ កើតឆ្នាំខាល អាយុ ៣៦ វស្សា-១៥ ជាចៅអធិការវត្តឈូកក់ ឃុំគោកគោ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កេត-ហ៊ម នាមឆាយា ព្រហ្មបញ្ញា កើតឆ្នាំច អាយុ ៤០ វស្សា ៩ ជាចៅអធិការវត្តអគ្គមេត្រី ឃុំព្រៃវែង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទឹម-ទាំ នាមឆាយា ធម្មជោត កើតឆ្នាំរកា អាយុ ៣០ វស្សា ១ ជាចៅអធិការវត្តបុស្សសាញ់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាឌ-យោក នាមឆាយា ធម្មបាល កើតឆ្នាំរោង អាយុ ៥៨ វស្សា ៣០ ជាចៅអធិការវត្តលម្ពលីវ័ន ឃុំកាកាប ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រ ៧០២ ចុះថ្ងៃសុក្រ ៣ កើតខែស្រាពណ៍ ឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៩២ តាំងលោកគ្រូ ណុប-ឌុយ នាមឆាយា ធម្មនិយ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៦ ជាចៅអធិការវត្តមុនីសាគរ ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៧០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទី-ពង់ នាមឆាយាសុវណ្ណត្ថេរ កើតឆ្នាំខាល អាយុ ៣៦ វស្សា ១៥ ជាចៅអធិការវត្តពោធិមាស ឃុំអម្ពិលតាពក ស្រុកកោះសុទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៧០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹម-ស៊ូ នាមឆាយា អគ្គត្ថេរ កើតឆ្នាំកុរ អាយុ ៣៩ វស្សា ៩ ជាគ្រូសូត្រស្តាំវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧០៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គុង-បួង នាមឆាយា បទ្មកេសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៦ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១០ ចុះថ្ងៃសុក្រ ៣ កើតខែភទ្របទឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៩២ តាំងលោកគ្រូ ខោល-ឃុន នាមឆាយា ពុទ្ធត្ថេរ កើតឆ្នាំច អាយុ ៦៥ វស្សា ២៦ ជាចៅអធិការវត្តសំពៅប៊ូ ឃុំមង់ការ ស្រុកត្បូងឃ្មុំ ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ធាន-ប៉ាត់ នាមធាយា ធម្មបាល កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣១ ជាគ្រូសូត្រស្តាំវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេក-សុទ្ធ នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំរកា អាយុ ២១ វស្សា ១ ជាចៅអធិការវត្តពោធិ៍ទន្ទឹម ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៧១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លាវ-ឡេង នាមធាយា ពុទ្ធលិក្ខិត កើតឆ្នាំរោង អាយុ ៥៨ វស្សា ២០ ជាចៅអធិការវត្តព្រែកប្រា ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៧១៤ ចុះថ្ងៃចន្ទ ៥ កើតខែកត្តិក ឆ្នាំឆ្លូវឯក-ស័ក ព. ស. ១៤៩២ តាំងលោកគ្រូ ប៊ូ-ដៀប នាមធាយា ចន្ទត្ថេរ កើតឆ្នាំរោង អាយុ ៤៦ វស្សា ២៤ ជាចៅអធិការវត្តសុវណ្ណារាម ឃុំព្រែកម្ទេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៧១៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុន-ជាង នាមធាយា វិជយត្ថេរ កើតឆ្នាំ... អាយុ ៣៣ វស្សា ៣១ ជាចៅអធិការវត្តព្រៃអង្គ ឃុំប្រសូត ស្រុក-ខេត្តដដែល ។

(មានត)

ÉCOLE FRANÇAISE

## កែពាក្យខុសក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៥០

### សៀវភៅលេខ ១០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ហានសង្ឃ្យម | មានសង្ឃ្យឹម | ៧២១ | ១២ |
| អត្តាចិនភាព | អត្តាធីនភាព | ៧៣១ | ៧ |
| មធុហេមរោគ | មធុមេហរោគ | ៧៣២ | ២ |
|  | (មានត) | ៧៦៧ | ១២ |

### សៀវភៅលេខ ១១

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| នៅមជ្ឈិមប្រទេស | នៅបច្ចិមប្រទេស | ៨១៦ | ២ |
| នីតិវិទី | នីតិវិធី | ៨២៥ | ១៩ |
| សង្កម៉ក— | សង្គម៉ក— | ៨២៦ | ១០ |
| រើសអ្ហើង | រើសអើង | ៨២៨ | ២ |
| បក្សាគ្រួចប្រកបាន | បក្សាគ្រួចដ្រកបាន | ៨៥៣ | ២ |
| Xeptre | Sceptre | ៨៥៥ | ១៤ |
| កិត្តនាម | កិត្តិនាម | ៨៨០ | ១៥ |